# ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ

## សៀវភៅព័ត៌មានសម្រាប់ប្រជាពលរដ្ឋ




## សិទ្ធិ និងស្តង់ដា ការបំពេញមុខងារ ថវិកា


គជអប NCDD
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ក្រសួងមហាផ្ទៃ មហាវិថីនរោត្តម ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ: (៨៥៥) ២៣ ៧២០ ០៣៨, ៧២០ ០៦១
អ៊ីម៉ែល: info@ncdd.gov.kh វែបសាយ: www.ncdd.gov.kh




## ក្រុមប្រឹក្សាដែលជាប់ឆ្នោតនៅឃុំ

អ្នកត្រូវទៅចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅរៀងរាល់៥ឆ្នាំម្តង ដើម្បីធ្វើជាតំណាងក្នុងឃុំរបស់អ្នក

អ្នកអាចរំពឹងថាក្រុមប្រឹក្សាឃុំដែលជាតំណាងរបស់អ្នកនឹងស្តាប់នូវយោបល់របស់អ្នក។

- ក្រុមប្រឹក្សានឹងធានាអោយមានការប្រជុំជាមួយភូមិជារៀងរាល់ខែ និងប្រចាំឆ្នាំ ដើម្បីស្តាប់មតិយោបល់អ្នក អំពីការប្រើប្រាស់ថវិកាឃុំ និងអញ្ជើញអ្នកចូលរួមកិច្ចប្រជុំក្រុមប្រឹក្សារៀងរាល់ខែ។
- ក្រុមប្រឹក្សាឃុំ ត្រូវតែជូនដំណឹង និងបិទផ្សាយជាសាធារណៈ អំពីកាលបរិច្ឆេទកិច្ចប្រជុំ របៀបវារៈ ប្រធានបទ និងកំណត់ហេតុកិច្ចប្រជុំ នៅលើក្តារព័ត៌មានឃុំ។

នៅក្នុងកិច្ចប្រជុំនេះ ក្រុមប្រឹក្សានឹងធ្វើការសម្រេចចិត្តអំពី៖
- បញ្ហានៅក្នុងឃុំរបស់អ្នក និងវិធីដោះស្រាយបញ្ហាទាំងនោះ
- ថវិកាត្រូវចំណាយយ៉ាងដូចម្តេច ដើម្បីអនុវត្តផែនការឃុំ។

- អ្នកអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំ មានសិទ្ធិផ្តល់យោបល់ និងសួរសំណួរ អំពីការផ្តល់សេវា និងគម្រោងនានា
- អ្នកអាចសួរនាំក្រុមប្រឹក្សាដើម្បីឲ្យប្រាកដអំពីប្រធានបទដែលត្រូវពិភាក្សានៅក្នុងកិច្ចប្រជុំ។

អ្នកអាចរំពឹងថាក្រុមប្រឹក្សានឹងឆ្លើយតបនូវកង្វល់របស់អ្នក និងផ្តល់ព័ត៌មានដល់អ្នកអំពីអ្វីដែលបានសម្រេចចិត្ត

- អ្នកអាចធ្វើការទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំឲ្យជួយដោះស្រាយបញ្ហា តម្រូវការ ឆ្លើយតបចំពោះបណ្តឹងតវ៉ា ឆ្លើយតបទៅនឹងសំណួរនានា អំពីសេវាកម្មឃុំ និងគម្រោងអភិវឌ្ឍន៍ឃុំ
- អ្នកអាចរកបាននូវព័ត៌មានដែលក្រុមប្រឹក្សាឃុំរបស់អ្នកបានសម្រេចនៅក្នុងកិច្ចប្រជុំ។ ប្រសិនបើអ្នកមិនអាចចូលរួមកិច្ចប្រជុំនេះបាន ប្រធានភូមិរបស់អ្នកគួរតែផ្តល់ព័ត៌មានដល់អ្នកអំពីអ្វីដែលបានកើតឡើងនៅក្នុងកិច្ចប្រជុំ។
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំ ត្រូវបានបិទនៅក្នុងភូមិរបស់អ្នក និងលើក្តារព័ត៌មាននៅសាលាឃុំ។

## សេវាអត្រានុកូលដ្ឋាន

ឃុំត្រូវចេញសំបុត្រកំណើត សំបុត្រមរណភាព និងសំបុត្រអាពាហ៍ពិពាហ៍ និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទក្នុងឆ្នាំ។ មេឃុំជាមន្ត្រីអត្រានុកូលដ្ឋានដែលអាចពន្យល់សេវាទាំងនេះដល់អ្នក។ អ្នកអាចសួរនាំព័ត៌មានពីគាត់ប្រសិនបើត្រូវការ។

### សំបុត្រកំណើត

ប្រសិនបើអ្នកផ្តល់នូវឯកសារគ្រប់គ្រាន់ទៅកាន់រដ្ឋបាលឃុំ អ្នកនឹងទទួលបានសំបុត្រកំណើតក្នុងរយៈពេល៣ថ្ងៃ នៃថ្ងៃធ្វើការ។

- ការចេញសំបុត្រកំណើតនេះត្រូវធ្វើឡើងដោយឥតគិតថ្លៃ។ សូមកុំចំណាយលុយឲ្យសោះ!
- យោងតាមច្បាប់ អ្នកត្រូវធ្វើសំបុត្រកំណើតកូនរបស់អ្នកក្នុងអំឡុងពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃទារកកើត។

**ឯកសារដែលអ្នកត្រូវមាន នៅពេលធ្វើសំបុត្រកំណើត៖**

- សំបុត្រពីមន្ទីរពេទ្យ មណ្ឌលសុខភាព ឬប្រធានភូមិ
- សៀវភៅគ្រួសារដែលមានឈ្មោះឪពុកម្តាយរបស់ទារក
- សំបុត្រអាពាហ៍ពិពាហ៍របស់ឪពុកម្តាយទារក ប្រសិនបើពួកគេបានរៀបអាពាហ៍ពិពាហ៍
- ប្រសិនបើអ្នកមិនបានធ្វើសំបុត្រកំណើតក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃទារកកើត អ្នកត្រូវបង់ថ្លៃ ១០.០០០រៀល សម្រាប់ធ្វើសំបុត្របញ្ជាក់កំណើត
- ការធ្វើសេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត មានតម្លៃ ៣.០០០ រៀល ក្នុង ០១សន្លឹក

### សំបុត្រមរណភាព

ប្រសិនបើអ្នកផ្តល់ឯកសារគ្រប់គ្រាន់ទៅឲ្យរដ្ឋបាលឃុំ អ្នកនឹងទទួលបានសំបុត្រមរណភាពក្នុងរយៈពេល៣ថ្ងៃ នៃថ្ងៃធ្វើការ។

- ការចេញសំបុត្រមរណភាពនេះត្រូវធ្វើឡើងដោយឥតគិតថ្លៃ។ សូមកុំចំណាយលុយឲ្យសោះ!
- យោងតាមច្បាប់អ្នកត្រូវធ្វើសំបុត្រមរណភាពក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលមរណភាព។

**ឯកសារដែលអ្នកត្រូវមាន នៅពេលធ្វើសំបុត្រមរណភាព៖**

- លិខិតបញ្ជាក់មរណភាពពីមន្ទីរពេទ្យ ឬលិខិតព័ត៌មានអំពីមរណភាពបញ្ជាក់ដោយអាជ្ញាធរពាក់ព័ន្ធដូចជា៖ ប្រធានភូមិ ឬប៉ុស្តិ៍នគរបាលរដ្ឋបាលជាដើម
- ប្រសិនបើអ្នកមិនបានធ្វើសំបុត្រមរណភាពក្នុងរយៈពេល៣០ថ្ងៃគិតចាប់ពីថ្ងៃស្លាប់ អ្នកត្រូវបង់ថ្លៃ ៣.០០០ រៀល។ ប្រសិនបើអ្នកមិនបានធ្វើសំបុត្រមរណភាពក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីថ្ងៃស្លាប់ អ្នកត្រូវតែមានសាលក្រមបញ្ជាក់ពីតុលាការ។
- សេចក្តីចម្លងសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព មានតម្លៃ ៣.០០០ រៀល ក្នុង ០១សន្លឹក

### សំបុត្រអាពាហ៍ពិពាហ៍

ប្រសិនបើអ្នកផ្តល់ឯកសារគ្រប់គ្រាន់ទៅឲ្យរដ្ឋបាលឃុំ អ្នកនឹងទទួលបានសំបុត្រអាពាហ៍ពិពាហ៍ក្នុងរយៈពេល៣ថ្ងៃ នៃថ្ងៃធ្វើការ។

- សំបុត្រអាពាហ៍ពិពាហ៍មានតម្លៃ ១៥.០០០ រៀល។ អ្នកមិនត្រូវចំណាយលើសពីតម្លៃសេវាដែលបានកំណត់ដោយច្បាប់។
- យោងតាមច្បាប់ អ្នកត្រូវធ្វើសំបុត្រអាពាហ៍ពិពាហ៍ បន្ទាប់ពីថ្ងៃបិទប័ណ្ណប្រកាសរៀបអាពាហ៍ពិពាហ៍ រយៈពេល១០ថ្ងៃ

**ឯកសារដែលអ្នកត្រូវមាន នៅពេលធ្វើសំបុត្រអាពាហ៍ពិពាហ៍៖**

- សំបុត្រកំណើតរបស់ប្តី និងសំបុត្រកំណើតរបស់ប្រពន្ធ
- សៀវភៅគ្រួសារ
- ប្រសិនបើធ្លាប់លែងលះ ត្រូវមានសាលក្រមពីតុលាការ។ ប្រសិនបើពោះម៉ាយ ឬម៉េម៉ាយ ត្រូវមានសំបុត្របញ្ជាក់មរណភាពប្តី ឬប្រពន្ធដែលស្លាប់។

## ការបិទបង្ហាញព័ត៌មានជាសាធារណៈ

អ្នកអាចរំពឹងថា ឃុំនឹងបិទផ្សាយនូវព័ត៌មានជាសាធារណៈអំពីសកម្មភាព និងហិរញ្ញវត្ថុឃុំ រួមមាន៖

- ផែនការឃុំ ថវិកាឃុំ និងព័ត៌មានអំពីគម្រោងអភិវឌ្ឍន៍
- ម៉ោងធ្វើការរបស់ឃុំ
- តារាងតម្លៃសេវា និងរបាយការណ៍នានា

**តើអ្នកមានយោបល់អ្វីដែរឬទេ? មានជម្រើសចំនួន៣ សម្រាប់អ្នក៖**

- អ្នកអាចនិយាយទៅកាន់ក្រុមប្រឹក្សាឃុំរបស់អ្នក
- អ្នកអាចលើកយោបល់ក្នុងកិច្ចប្រជុំតាមដានរបស់សហគមន៍ជាមួយនឹងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ហើយបញ្ហាទាំងនេះនឹងត្រូវបានបញ្ចូលទៅក្នុងប័ណ្ណដាក់ពិន្ទុសហគមន៍
- អ្នកអាចប្រើប្រាស់ប្រអប់គណនេយ្យភាពនៅក្នុងឃុំរបស់អ្នក។

# ការបំពេញការងាររបស់ឃុំ

រូបភាពផ្ទាំងធំនេះនឹងផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋអំពីការបំពេញភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ។
អ្នកអាចពិនិត្យមើលថាតើឃុំរបស់អ្នកកំពុងធ្វើអ្វី? តើគេធ្វើយ៉ាងដូចម្តេច?
ហើយអ្នកអាចផ្តល់យោបល់ ដើម្បីជួយឃុំរបស់អ្នកក្នុងការកែលម្អសេវាដែលផ្តល់ដោយពួកគេ និងមុខងារដែលគេបំពេញ។




## ការទទួលខុសត្រូវរបស់ឃុំ

ឃុំរបស់អ្នកមានការទទួលខុសត្រូវចម្បងចំនួន៣៖

### ជាតំណាង និងការធ្វើសេចក្តីសម្រេចចិត្ត

- អ្នកអាចរំពឹងថាក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោតនឹងក្លាយជាតំណាងរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងឃុំ និងធ្វើការឆ្លើយតបនូវតម្រូវការ និងក្តីកង្វល់របស់ប្រជាពលរដ្ឋ។

### អត្រានុកូលដ្ឋាន

- អ្នកអាចរំពឹងថាក្រុមប្រឹក្សាឃុំនឹងចុះបញ្ជីសំបុត្រកំណើត សំបុត្រមរណភាព និងសំបុត្រអាពាហ៍ពិពាហ៍។

### ការរៀបចំចាត់ចែងថវិកាអភិវឌ្ឍន៍ឃុំ

- អ្នកអាចរំពឹងថាក្រុមប្រឹក្សាឃុំនឹងពិគ្រោះយោបល់ជាមួយអ្នក
- អ្នកអាចរំពឹងថាក្រុមប្រឹក្សាឃុំនឹងរៀបចំចាត់ចែងថវិកាឃុំ ដោយការធ្វើផែនការសកម្មភាព ផែនការថវិកា និងចំណាយលើគម្រោង និងសេវាដែលបានព្រមព្រៀង។

### តើអ្នកមានយោបល់អ្វីដែរឬទេ? មានជម្រើស៣ សម្រាប់អ្នក៖

- អ្នកអាចនិយាយទៅកាន់ក្រុមប្រឹក្សាឃុំរបស់អ្នក។
- អ្នកអាចពន្យល់អំពីបញ្ហានៅក្នុងកិច្ចប្រជុំតាមដានរបស់សហគមន៍ជាមួយនិងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ហើយបញ្ហាទាំងនេះនឹងត្រូវបានបញ្ចូលទៅក្នុងប័ណ្ណដាក់ពិន្ទុសហគមន៍
- អ្នកអាចប្រើប្រាស់ប្រអប់គណនេយ្យភាពនៅក្នុងឃុំរបស់អ្នក

## តើអ្វីទៅជាស្តង់ដារនៃការបំពេញការងាររបស់ឃុំ?

ក្រុមប្រឹក្សាឃុំបានសម្រេចចិត្តក្នុងការត្រួតពិនិត្យថាតើខ្លួនបានបំពេញមុខងារសំខាន់ ចំនួន៥ យ៉ាងដូចម្តេច?

ដើម្បីយល់អំពីស្តង់ដារនេះ អ្នកត្រូវដឹងអំពីអ្វី ដែលក្រុមប្រឹក្សាត្រូវបំពេញភារកិច្ចដើម្បីប្រជាពលរដ្ឋ។

- ក្រុមប្រឹក្សាឃុំត្រូវធានាថាកិច្ចប្រជុំត្រូវបានរៀបចំឡើងនៅតាមភូមិនីមួយៗ ដើម្បីពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋជារៀងរាល់ឆ្នាំក្នុងដំណើរការរៀបចំផែនការឃុំ។
- ក្រុមប្រឹក្សាត្រូវប្រជុំប្រចាំខែចំនួន១២ដងក្នុង១ឆ្នាំ និងបិទបង្ហាញនូវកាលបរិច្ឆេទប្រជុំ ម៉ោងប្រជុំ និងប្រធានបទនៃកិច្ចប្រជុំ ដែលធ្វើអោយអ្នកអាចចូលរួមកិច្ចប្រជុំបាន។
- ក្រុមប្រឹក្សាឃុំនឹងចេញសំបុត្រកំណើត សំបុត្រមរណភាព និងសំបុត្រអាពាហ៍ពិពាហ៍ក្នុងរយៈពេល៣ ថ្ងៃ យ៉ាងហោចណាស់បាន៨០% នៃចំនួនសរុប ប្រសិនបើអ្នកបានផ្តល់នូវឯកសារត្រឹមត្រូវ និងបង់ថ្លៃសំបុត្រអាពាហ៍ពិពាហ៍តាមតម្លៃសេវាដែលបានកំណត់។
- ក្រុមប្រឹក្សាឃុំនឹងបិទបង្ហាញព័ត៌មានជាសាធារណៈចំនួន៦ (ផែនការវិនិយោគ ថវិកាប្រចាំឆ្នាំ ព័ត៌មានគម្រោងដែលបានអនុម័ត ម៉ោងធ្វើការ សេវា និងតម្លៃ)
- ក្រុមប្រឹក្សានឹងបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងសម្រាប់គ្រប់គ្រងគម្រោងរបស់ឃុំ។ គណៈកម្មការនោះរួមមានមេឃុំ សមាជិកគណៈកម្មការលទ្ធកម្ម និងតំណាង១រូបមកពីភូមិនីមួយៗ ដែលទទួលផលពីគម្រោងនោះ។ គណៈកម្មការនេះមានតួនាទីផ្តល់យោបល់ជូនមេឃុំ ចូលរួមក្នុងការរៀបចំគម្រោង យល់ដឹងពីលទ្ធផលរំពឹងទុករបស់គម្រោង និងជួយតាមដានការរីកចម្រើននៃគម្រោងឃុំ និងដោះស្រាយបញ្ហានានាដែលអាចកើតឡើង។ ពួកគេនឹងផ្តល់ព័ត៌មាន និងព័ត៌មានត្រឡប់ដល់ប្រជាពលរដ្ឋ ប្រសិនបើពួកគេមានសំណួមពរ។
- ក្រុមប្រឹក្សានឹងគាំទ្រការចូលរួមរបស់ប្រជាពលរដ្ឋ និងគណនេយ្យភាពសង្គមនៅក្នុងឃុំ

អ្នកអាចពិនិត្យមើលថាតើឃុំរបស់អ្នកកំពុងធ្វើអ្វី? តើពួកគេបានបំពេញនូវស្តង់ដារទាំងនេះឬទេ? ហើយអ្នកអាចផ្តល់យោបល់ដើម្បីជួយឃុំកែលម្អលើសេវាដែលឃុំផ្តល់ និងមុខងារដែលឃុំបានអនុវត្ត។

## ពិនិត្យមើលការបំពេញការងារឃុំរបស់អ្នក

តើក្រុមប្រឹក្សាឃុំរបស់អ្នកបំពេញការងារបានល្អឬទេ?

ទាំងនេះគឺជាឧទាហរណ៍ខ្លះ ដោយប្រៀបធៀបការបំពេញការងារឃុំរបស់អ្នកដែលបានធ្វើកាលពីឆ្នាំមុន។

### តើក្រុមប្រឹក្សាឃុំអ្នកបានរៀបចំកិច្ចប្រជុំប្រចាំខែដែរឬទេ?

ក្រុមប្រឹក្សាឃុំរបស់អ្នកត្រូវរៀបចំកិច្ចប្រជុំចំនួន១២ដងក្នុង១ឆ្នាំ ដើម្បីធ្វើសេចក្តីសម្រេច

**X មិនទាន់ទេ**

នៅឆ្នាំ២០១៩ ក្រុមប្រឹក្សាឃុំបានរៀបចំកិច្ចប្រជុំចំនួន១០ នៃកិច្ចប្រជុំសរុបចំនួន១២ ស្មើនឹង៨៣%

### តើឃុំរបស់អ្នកបានពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែរឬទេ?

ក្រុមប្រឹក្សាឃុំរបស់អ្នកត្រូវធានាថាកិច្ចប្រជុំត្រូវបានរៀបចំឡើងនៅគ្រប់ភូមិ ដើម្បីពិគ្រោះយោបល់អំពីថវិកាឃុំត្រូវចំណាយលើអ្វីខ្លះ។

**✓ បាទ/ចាស**

នៅឆ្នាំ២០១៩ ក្រុមប្រឹក្សាឃុំបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់នៅភូមិចំនួន៩ក្នុងចំណោមភូមិចំនួន៩ ស្មើនឹង១០០%

### តើឃុំរបស់អ្នកបានបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងដែរឬទេ?

ឃុំរបស់អ្នកត្រូវបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងដែលមានតំណាងសហគមន៍ជួយក្នុងការរៀបចំ និងត្រួតពិនិត្យគម្រោង

**✓ បាទ/ចាស**

នៅឆ្នាំ២០១៩ មានគម្រោងចំនួន៣ នៃចំនួនគម្រោងសរុប៣បានបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងស្មើនឹង១០០%

# ថវិកាឃុំ

រូបភាពផ្ទាំងធំខាងក្រោមនេះ នឹងផ្តល់ព័ត៌មានដល់អ្នកអំពីថវិកាដែលឃុំចាត់ចែង។ ព័ត៌មាននេះ ត្រូវបានរៀបចំឡើងដោយឃុំរបស់អ្នក។ អ្នកអាចពិនិត្យមើលថាតើឃុំរបស់អ្នកចំណាយយ៉ាងដូចម្តេចលើថវិកាឃុំនេះ។




## ថវិកាឃុំរបស់អ្នក

## តើឃុំអ្នកទទួលបានថវិកាមកពីប្រភពណាខ្លះ?

ព័ត៌មាននេះបង្ហាញថវិកាមានប្រភពមកពីណា ដែលរួមមាន៖

- ការផ្ទេរថវិកាពីថ្នាក់ជាតិ (មូលនិធិឃុំ សង្កាត់)
- ថ្លៃផ្តល់សេវា ពោលគឺថវិកាដែលឃុំទទួលបានពីកិច្ចការអត្រានុកូលដ្ឋាន និងសេវាកម្មផ្សេងៗ។
- ជំនួយ និងការបរិច្ចាគ ដែលរួមមានថវិកាដែលបានទទួលនៅក្នុងគណនីរបស់ឃុំពីម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល ការបរិច្ចាគជាឯកជន និងថវិកាសម្រាប់ការងារសង្គ្រោះបន្ទាន់
- ការរួមចំណែកពីសហគមន៍ ដែលជាថវិកាដែលបានមកពីសហគមន៍សម្រាប់គោលបំណងជាក់លាក់មួយ។

## តើការប្រើផ្តល់មូលនិធិដល់ឃុំរបស់អ្នកមានការកើនឡើងដែរឬទេ?

ដោយប្រៀបធៀបមូលនិធិសរុបដែលឃុំអ្នកទទួលបានរយៈពេល ២ឆ្នាំកន្លងមក ជាមួយនឹងមូលនិធិសរុបដែលទទួលបានក្នុងឆ្នាំមុន។ អ្នកអាចមើលឃើញថា មូលនិធិឃុំរបស់អ្នកទទួលបានច្រើន ឬតិចជាងមុន។

## ការចំណាយ

តើឃុំអ្នកបានប្រើប្រាស់ថវិកាយ៉ាងដូចម្តេចកាលពីឆ្នាំមុន?
ដោយធ្វើការប្រៀបធៀបថវិកាដែលបានអនុម័តដោយឃុំ កាលពីឆ្នាំកន្លងមក និង ចំណាយជាក់ស្តែងធៀបទៅនឹងចំណាយជាក់ស្តែងលើផផ្នែក

### ឃុំ ខ (2014)

២

#### តើឃុំរបស់អ្នកចំណាយថវិកាយ៉ាងដូចម្តេច ?

| | ថវិកាគ្រោង | ចំណាយ | គិតជា% |
|---|---|---|---|
| អភិវឌ្ឍន៍ | 26,456,800 | 26,456,800 | 100% |
| ■ **ហេដ្ឋារចនាសម្ព័ន្ធ**<br>ការសាងសង់ និងកែលម្អផ្សេងៗ ឧ. ផ្លូវ ប្រព័ន្ធធារាសាស្ត្រ | 25,891,000 | 25,891,000 | 100% |
| ■ **សេវាសង្គម**<br>សុខាភិបាល អប់រំ ឧបត្ថម្ភអ្នកក្រីក្រ ការគ្រប់គ្រងគ្រោះមហន្តរាយ។ល។. | 565,800 | 565,800 | 100% |
| រដ្ឋបាល | 20,900,000 | 20,900,000 | 100% |
| ■ **ប្រាក់ខែ និងប្រាក់ឧបត្ថម្ភផ្សេងៗ**<br>ក្រុមប្រឹក្សាឃុំ គណៈកម្មការភូមិ | 17,450,000 | 17,450,000 | 100% |
| ■ **ចំណាយប្រតិបត្តិការ**<br>ថ្លៃទឹក ភ្លើង ការធ្វើដំណើរ និងផ្សេងៗ | 3,450,000 | 3,450,000 | 100% |
| **ចំណាយសរុប** | **47,356,800** | **47,356,800** | **100%** |

**ឃុំរបស់អ្នកគ្រោងនឹងចំណាយ 56%នៃថវិកាសរុបសម្រាប់ការអភិវឌ្ឍ**

ព័ត៌មាននេះនឹងបង្ហាញអំពីថវិកាដែលបានចំណាយដែលរួមមាន៖

- ចំណាយលើហេដ្ឋារចនាសម្ព័ន្ធ
- ចំណាយលើសេវាសង្គម
- ចំណាយលើប្រាក់បៀវត្ស និងការឧបត្ថម្ភផ្សេងៗ
- ចំណាយប្រតិបត្តិការ

**សរុប៖** បូកសរុបថវិកាដែលបានគ្រោងកាលពីឆ្នាំមុនធៀបទៅនឹងថវិកាដែលបានចំណាយដោយបង្ហាញនូវភាគរយដែលបានចំណាយ។

# ថវិកាឃុំ




## ពិនិត្យគម្រោងអភិវឌ្ឍន៍ឃុំរបស់អ្នក

អ្នកអាចចូលរួម និងស្វែងយល់អំពីការធ្វើកម្មវិធីវិនិយោគឃុំក្នុងឆ្នាំនីមួយៗ។ កម្មវិធីវិនិយោគឃុំប្រើប្រាស់ថវិការបស់រដ្ឋដើម្បីដោះស្រាយតម្រូវការអាទិភាពរបស់ឃុំ ហើយក្នុងនាមជាប្រជាពលរដ្ឋនៃសហគមន៍ក្នុងឃុំ អ្នកមានសិទ្ធិចូលរួមក្នុងការធ្វើផែនការឃុំ និងត្រួតពិនិត្យការអនុវត្តផែនការ និងកម្មវិធីវិនិយោគឃុំ។

## ផែនការអភិវឌ្ឍន៍ឃុំរបស់អ្នក

ក្រុមប្រឹក្សាឃុំនឹងបង្ហាញនូវសេចក្តីព្រាងកម្មវិធីវិនិយោគ និងថវិកាដល់ប្រជាពលរដ្ឋនៅក្នុងការប្រជុំពិភាក្សាជាសាធារណៈ។

- សេចក្តីព្រាងផែនការនឹងចាត់នូវបញ្ហាអាទិភាពរបស់ភូមិណាខ្លះដែលត្រូវទទួលបានថវិកា ដើម្បីដោះស្រាយនៅឆ្នាំបន្ទាប់។
- តារាងចាត់អាទិភាពនេះនឹងបិទនៅលើក្តារព័ត៌មានឃុំ ដែលប្រជាពលរដ្ឋអាចមើលឃើញបញ្ហាអាទិភាពទាំងនោះ និងការសម្រេចចិត្ត។

## គម្រោងឃុំ

- តើគម្រោងអ្វីខ្លះ ដែលក្រុមប្រឹក្សាឃុំបានអនុម័តក្នុងការផ្តល់ថវិកា? ជារៀងរាល់ឆ្នាំ ឃុំរបស់អ្នកបានសម្រេចថា តើគម្រោងណា ដែលត្រូវវិភាជន៍ សម្រាប់ការអភិវឌ្ឍដោយមូលនិធិឃុំ ដែលរួមមាន៖ គម្រោងហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវលំ ស្ពាន លូ។ល។) អ្នកត្រូវតែដឹងថា ឃុំតែងតែទទួលបានថវិកាមិនទាន់ពេលវេលា ហើយគម្រោងមួយចំនួនអាចត្រូវបញ្ចប់នៅឆ្នាំបន្ទាប់។
- តារាងនេះរំលេចឲ្យឃើញនូវបញ្ជីគម្រោង ដែលត្រូវបានជ្រើសរើសឡើងដោយក្រុមប្រឹក្សាឃុំ ដែលបានអនុវត្តរយៈពេល២ឆ្នាំកន្លងមក។ គម្រោងនីមួយៗមានការរៀបរាប់ខ្លីៗពីលទ្ធផលរំពឹងទុក និងបង្ហាញនូវស្ថានភាពនៃការអនុវត្ត ថាតើគម្រោងត្រូវបានបញ្ចប់ ឬកំពុងអនុវត្ត ឬក៏មិនទាន់បានជ្រើសរើសបាននៅឡើយ។

## ការជ្រើសរើសគម្រោង

## ការដេញថ្លៃ

អ្នកអាចស្វែងយល់ថា តើក្រុមប្រឹក្សាឃុំអ្នកជ្រើសរើសអ្នកទទួលការក្នុងការអនុវត្តគម្រោងយ៉ាងដូចម្តេច? ល័ក្ខខ័ណ្ឌជាមូលដ្ឋានមួយចំនួនដូចជា៖

- រាល់ការដេញថ្លៃគម្រោងទាំងអស់ត្រូវតែផ្សព្វផ្សាយជាសាធារណៈ ហើយអ្នកទទួលការត្រូវចូលរួមដេញថ្លៃគម្រោងអភិវឌ្ឍន៍នេះ។
- ដំណើរការជ្រើសរើសអ្នកទទួលការត្រូវអនុវត្តតាមសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (PIM)។
- ព័ត៌មាន (ក្រុមហ៊ុន ឬអ្នកឈ្នះក្នុងការដេញថ្លៃ ពេលវេលា ការចាប់ផ្តើមអនុវត្ត ពេលវេលាបញ្ចប់ និងតម្លៃគម្រោង) ត្រូវតែផ្សព្វផ្សាយជាសាធារណៈនៅក្តារព័ត៌មានឃុំ និងលើគេហទំព័រ គ.ជ.អ.ប។

## ការត្រួតពិនិត្យគម្រោង

# គម្រោង ឃុំ ខ

៣

ជារៀងរាល់ឆ្នាំ ឃុំអ្នក បានពិគ្រោះយោបល់ជាមួយអ្នក ដើម្បីធ្វើផែនការ និងចាត់អាទិភាពគម្រោងនិងសកម្មភាព។ គម្រោងទាំងនេះ រួមមាន កសាងហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវ ស្ពាន លូ) គាំទ្រសេវាកម្មសង្គម ដូចជា ផ្នែកសុខភាព អប់រំ និងផ្តល់ថវិកាជួយដល់អ្នកក្រីក្រ។ ភាគច្រើន នៃថវិកាសម្រាប់គម្រោងអភិវឌ្ឍន៍ទាំងនេះ បានមកពីរាជរដ្ឋាភិបាលតាមរយៈ" មូលនិធិឃុំ សង្កាត់" ដោយសារតែ មានការពន្យាពេល ក្នុងការទម្លាក់ថវិកា និងដោយសារតែ រដូវភ្លៀង គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្លះ ត្រូវចំណាយពេល២ឆ្នាំដើម្បីបញ្ចប់។

| គម្រោងឃុំ | ស្ថានភាពបច្ចុប្បន្ន |
|---|---|
| គម្រោងដែលបានគ្រោងថវិកាក្នុងឆ្នាំ2014 | |
| **សាងសង់ផ្លូវប្រវែង ៤ គីឡូម៉ែត្រនៅភូមិ ខ** | បញ្ចប់ |
| **ជួយពលរដ្ឋក្រីក្រចំនួន ៥០ នាក់ លើការងារសេវាសង្គម** | កំពុងដំណើរការ |
| **ផ្តល់ប្រាក់កម្ចីចំនួន ១.០០០.០០០ រៀល ដល់ក្រុមស្ត្រីងាយរងគ្រោះ** | មិនទាន់ចាប់ផ្តើម |

នៅទីតាំងអនុវត្តគម្រោង អ្នកអាចស្វែងយល់អំពី៖

- អ្នកណាជាសមាជិកគណៈកម្មការគ្រប់គ្រងគម្រោង?
- តើកិច្ចការអ្វីខ្លះដែលគណៈកម្មការត្រូវធ្វើ?
- តើការចំណាយត្រូវធ្វើឡើងយ៉ាងដូចម្តេច?
- តើគម្រោងត្រូវបានបញ្ចប់នៅពេលណា?
- ឈ្មោះ និងទំនាក់ទំនងរបស់ក្រុមហ៊ុនទទួលការ?

នៅពេលគម្រោងត្រូវបានបញ្ចប់ អ្នកត្រូវធ្វើកិច្ចការមួយចំនួន ដើម្បីប្រាកដថា គម្រោងត្រូវបានអនុវត្តត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស៖

- មុនពេលដែលអ្នកទទួលការទទួលថវិកាចុងក្រោយ គណៈកម្មការគ្រប់គ្រងគម្រោងត្រូវពិនិត្យថា តើកិច្ចការត្រូវបានអនុវត្តប្រកបដោយគុណភាពល្អត្រឹមត្រូវតាមកិច្ចសន្យា និងថវិកាដែលបានគ្រោងដែរឬទេ។
- ប្រសិនបើអ្នកមិនពេញចិត្តនឹងលទ្ធផលគម្រោង អ្នកអាចទាក់ទងទៅសមាជិកគណៈកម្មការគ្រប់គ្រងគម្រោង ដែលនឹងទទួលនូវមតិយោបល់ត្រលប់របស់អ្នកដោយក្តីរីករាយ។

តើអ្នកមានយោបល់អ្វីដែរឬទេ? មានជម្រើស៣ សម្រាប់អ្នក៖

- អ្នកអាចនិយាយទៅកាន់ក្រុមប្រឹក្សាឃុំរបស់អ្នក
- អ្នកអាចពន្យល់អំពីបញ្ហាទៅកាន់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍របស់អ្នក ហើយបញ្ចូលបញ្ហាទាំងនេះទៅក្នុងប័ណ្ណដាក់ពិន្ទុសហគមន៍
- អ្នកអាចប្រើប្រាស់ប្រអប់គណនេយ្យភាពនៅក្នុងឃុំរបស់អ្នក។

# សិទ្ធិរបស់ប្រជាពលរដ្ឋ

រូបភាពផ្ទាំងធំនេះ គឺជាប័ណ្ណព័ត៌មានដែលបរិយាយអំពីសិទ្ធិរបស់សិស្សនៅសាលាបឋមសិក្សា ដែលដកស្រង់ចេញពីផែនការយុទ្ធសាស្ត្រជាតិសម្រាប់វិស័យអប់រំឆ្នាំ២០១៤-២០១៨។




## សិទ្ធិរបស់អ្នកនៅសាលាបឋមសិក្សា

អ្នកមានសិទ្ធិនៅសាលាបឋមសិក្សាដូចតទៅ៖

**កុមារគ្រប់រូបមានអាយុចាប់ពី៦ឆ្នាំឡើងទៅ ត្រូវទទួលបានការសិក្សាដោយមិនបង់ថ្លៃរហូតដល់ចប់ថ្នាក់ទី៩**

- ត្រូវនាំកូនទៅចុះឈ្មោះចូលរៀន ចាប់ពីអាយុ ៦ឆ្នាំ ឬ៧០ខែ
- ការសិក្សាត្រូវបានផ្តល់ដោយមិនគិតថ្លៃ ចាប់ពីថ្នាក់ទី១ ដល់ចប់ថ្នាក់ទី៩

**សិទ្ធិទទួលបានគ្រូ១នាក់ដែលទទួលបន្ទុក១ថ្នាក់ មានសិស្ស ៤២នាក់**

- សិទ្ធិនេះនឹងធានាថា សិស្សគ្រប់រូបត្រូវទទួលបានការយកចិត្តទុកដាក់សមស្របពីគ្រូក្នុងការសិក្សា។ នៅពេលមានសិស្សលើលពី៤២នាក់ក្នុង១ថ្នាក់ ថ្នាក់នេះលើសចំនួនកំណត់។

**សិទ្ធិទទួលបានការបង្រៀនពីគ្រូរយៈពេល២២៨ថ្ងៃក្នុងមួយឆ្នាំ**

- សិស្សមានសិទ្ធិទទួលបានការសិក្សាពេញ២២៨ថ្ងៃ ដើម្បីធានាថាពួកគេមានពេលវេលាសិក្សាគ្រប់គ្រាន់នៅក្នុងថ្នាក់
- រៀងរាល់ឆ្នាំ គ្រូត្រូវបង្រៀន១៩០ថ្ងៃ ទៅតាមកម្មវិធីសិក្សាជាតិ និង៣៨ថ្ងៃសម្រាប់កម្មវិធីបំណិនជីវិត
- គ្រូគ្រប់រូបត្រូវមានវត្តមាននៅសាលារៀនជារៀងរាល់ថ្ងៃ និងត្រូវបង្រៀនពេញមួយថ្ងៃ

**សិស្សគ្រប់រូបមានសិទ្ធិខ្ចីសៀវភៅពុម្ពចំនួន៣ក្បាល ឬ៤ក្បាលដោយមិនបង់ថ្លៃ**

- សៀវភៅពុម្ពផ្តល់ប្រយោជន៍ឲ្យសិស្សអាចរៀនសូត្រទាំងនៅក្នុងថ្នាក់ និងនៅផ្ទះ
- សាលារៀននឹងឲ្យសិស្សខ្ចីសៀវភៅពុម្ពចំនួន ៣ក្បាលសម្រាប់សិស្សថ្នាក់ទី១ ដល់ថ្នាក់ទី៣ និងចំនួន៤ក្បាលសម្រាប់សិស្សថ្នាក់ទី៤ ដល់ថ្នាក់ទី៦

### សិទ្ធិប្រើប្រាស់បង្គន់អនាម័យដោយឡែកពីគ្នាសម្រាប់សិស្សស្រី និងសិស្សប្រុស

- សាលារៀនត្រូវផ្តល់ដល់សិស្សនូវបរិស្ថានស្អាត និងអនាម័យដែលបង្កលក្ខណៈឲ្យសិស្សបានរៀនសូត្រ និងមិនរំខានដល់ការសិក្សា
- សាលារៀនត្រូវមានបង្គន់អនាម័យផ្សេងគ្នាសម្រាប់សិស្សស្រី និងសិស្សប្រុស ប្រព័ន្ធគ្រប់គ្រងកាកសំណល់ សម្ភារៈសង្គ្រោះបឋម និងការទទួលបានទឹកអនាម័យប្រកបដោយសុវត្ថិភាព

### គ្រូត្រូវយកចិត្តទុកដាក់ក្នុងកម្រិតខ្ពស់ ដើម្បីជួយសិស្សក្នុងការសិក្សា

- គ្រូត្រូវយកចិត្តទុកដាក់បង្រៀនសិស្សគ្រប់ៗគ្នា គ្មានការរើសអើងភេទ ដើមកំណើតជាតិសាសន៍ ពណ៌សម្បុរ ស្ថានភាពជីវភាព ភាពអសមត្ថភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត ជំងឺ អាយុ ភាសា សាសនា និងនិន្នាការនយោបាយ
- គ្រូត្រូវយកចិត្តទុកដាក់បង្រៀនសិស្សគ្រប់ៗគ្នាដោយជៀសវាងការដាក់ទណ្ឌកម្មលើរូបរាងកាយ
- គ្រូត្រូវជៀសវាង មិនឲ្យសិស្សបង់ ឬទទួលកម្រៃក្រៅផ្លូវការទេ (ដូចជាកម្រៃលើសៀវភៅសិក្ខាគារិក ឬដើម្បីបញ្ចប់ការសិក្សាជាដើម)
- គ្រូធ្វើទំនាក់ទំនងជាប្រចាំតាមរយៈផ្ទាល់មាត់ ឬតាមរយៈសៀវភៅតាមដានសិស្ស ជាមួយមាតាបិតា អាណាព្យាបាលសិស្ស ដើម្បីជូនដំណឹង និងចូលរួមជំរុញការសិក្សារបស់សិស្ស។

ការទទួលខុសត្រូវរបស់មាតាបិតា អាណាព្យាបាល និងសិស្ស ក៏ត្រូវមានការទទួលខុសត្រូវដើម្បីធានាថា ពួកគេទទួលបានការអប់រំប្រកបដោយគុណភាព

### អ្នកមានភារកិច្ចចំពោះសាលារៀន

- ត្រូវខិតខំសិក្សា និងប្រើប្រាស់សិទ្ធិរបស់ខ្លួន បើចាំបាច់ត្រូវហ៊ានសាកសួរឲ្យមានការបំភ្លឺ
- មានភារកិច្ចក្នុងការផ្តល់មតិយោបល់ ដើម្បីភាពរីកចម្រើនរបស់សាលារៀនជាលក្ខណៈបុគ្គល ឬតាមរយៈតំណាងដោយលើកឡើងពីបញ្ហា និងផលប្រយោជន៍

### មាតាបិតា ឬអ្នកអាណាព្យាបាលត្រូវរួមចំណែកក្នុងការរៀនសូត្ររបស់កូនៗ

- មាតាបិតា ឬអ្នកអាណាព្យាបាលត្រូវធានាថា កូនបានចុះឈ្មោះចូលរៀនចាប់ពីអាយុ៦ឆ្នាំ មិនត្រូវខកខាន ឬពន្យារពេលឡើយ
- មាតាបិតា ឬអ្នកអាណាព្យាបាលត្រូវធានាឲ្យកូនបានចូលរៀនរយៈ៩ឆ្នាំពេញនៃកម្រិតអប់រំជាមូលដ្ឋាន
- មាតាបិតា ឬអ្នកអាណាព្យាបាលត្រូវតាមដានការរៀនសូត្ររបស់កូន គ្រូ និងត្រូវតម្រែតម្រង់ពួកគេឲ្យមានគណនេយ្យភាពចំពោះសិទ្ធិ ស្តង់ដារនានា និងក្នុងករណីចាំបាច់ ត្រូវចូលរួមចំណែកកែលម្អឲ្យកាន់តែប្រសើរឡើង
- មាតាបិតា ឬអ្នកអាណាព្យាបាលត្រូវគោរពរាប់អានគ្រូរបស់កូនៗ ខ្លួនឲ្យបានស្មើៗគ្នា

### ក្នុងនាមជាសិស្សត្រូវៈ

- ធ្វើខ្លួនជាអ្នកសិក្សាប្រកបដោយប្រសិទ្ធភាព មករៀនឲ្យបាន ទៀងទាត់ ទាន់ពេលវេលា ធ្វើកិច្ចការដែលគ្រូដាក់ឲ្យ និងសុំឲ្យគ្រូជួយ នៅពេលចាំបាច់
- គោរពគ្រូឲ្យបានស្មើៗគ្នា
- ចូលរួមថែរក្សាទីធ្លាសាលារៀន ថ្នាក់រៀន និងសម្ភាររបស់សាលាឲ្យបានស្អាតជាប្រចាំ

# ថវិកាដំណើរការសាលារៀន

រូបភាពផ្ទាំងធំនេះ នឹងផ្តល់ព័ត៌មានអំពីថវិការបស់សាលា និងការសម្រេចបាន។
ព័ត៌មានទាំងនេះទទួលបានពីសាលារៀន។
លោកអ្នកអាចពិនិត្យមើលពីការប្រើប្រាស់ថវិការបស់សាលាបឋមសិក្សា។




## សារៈសំខាន់នៃការយល់ដឹងពីថវិកាដំណើរការសាលារៀន

### ចំណូល

តើកាលពីឆ្នាំកន្លងមកសាលារៀនទទួលបានថវិកាចំនួនប៉ុន្មាន?
ព័ត៌មាននេះនឹងឲ្យអ្នកយល់ថា ថវិកាប្រភេទណាដែល
សាលារៀនទទួលបានជាចំណូលសរុប

| ឃុំ ក -- បឋមសិក្សា គ (២០១៤) | | ១ |
|---|---|---|
| តើសាលាបឋមសិក្សារបស់អ្នកបានទទួលថវិកាប៉ុន្មាន? | | |
| ក្នុងឆ្នាំ២០១៤ សាលារបស់អ្នកបានទទួលថវិកាសរុប: | 48,260,500 | |
| ថវិកាបានមកពី | | |
| ■ ថវិកាជាតិ<br>ថវិកាដែលបានផ្ទេរពីរាជរដ្ឋាភិបាល | 34,000,000 | 70% |
| ■ ជំនួយកែលម្អសាលារៀន<br>ថវិកាដែលផ្តល់ដោយម្ចាស់ជំនួយអន្តរជាតិ | 12,670,000 | 26% |
| ■ ជំនួយ និងការបរិច្ចាក<br>ប្រភពនៃអំណោយ ឬការបរិច្ចាកមិនត្រូវបានដឹង | 590,500 | 1% |
| ■ ការរួមចំណែករបស់សហគមន៍<br>ប្រមូលបានពីសមាជិកសហគមន៍ | 1,000,000 | 2% |

| តើចំណូលសាលាមានការកើនឡើងឬទេ? | | តើសាលាបានទទួលថវិកាដូចការរំពឹងទុកដែរឬទេ? | |
|---|---|---|---|
| ? មិនដឹង | | ? មិនដឹង | |
| • ក្នុងឆ្នាំ ២០១៣ សាលាទទួលបាន | %. | • ក្នុងឆ្នាំ ២០១៤ សាលាគ្រោងទទួលបាន | |
| • ក្នុងឆ្នាំ ២០១៤ សាលាទទួលបាន | 48,260,500 | • ក្នុងឆ្នាំ ២០១៤ សាលាទទួលបាន | 48,260,500 |
| • កើនឡើង | មិនដឹង | • គិតជា%នៃថវិកាគ្រោង | មិនដឹង |

### តើថវិកាទាំងនេះបានមកពីប្រភពណា?

- ថវិកាជាតិ ជាថវិកាដែលបានផ្ទេរពីរាជរដ្ឋាភិបាល
- ថវិកាជំនួយកែលម្អសាលារៀន ជាថវិកាដែលផ្តល់ដោយម្ចាស់ជំនួយអន្តរជាតិ
- ជំនួយ និងការបរិច្ចាក ជាថវិកាដែលទទួលបានពីម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល និងការបរិច្ចាកពីសប្បុរសជនដែលប្រមូលពីសមាជិកសហគមន៍

### តើថវិកាដែលសាលារៀនទទួលបានមានការកើនឡើងដែរឬទេ?

ព័ត៌មាននេះនឹងបង្ហាញអ្នកអំពីថវិកាសរុប ដែលទទួលបានកាលពី ២ ឆ្នាំកន្លងមក ហើយនឹងឲ្យអ្នកដឹងថា ចំណូលមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំគិតជាភាគរយ

### តើសាលារៀនអ្នកបានទទួលថវិកាដូចការរំពឹងទុកដែរឬទេ?

ព័ត៌មាននេះនឹងបង្ហាញអ្នកអំពីថវិកាសរុបដែលរំពឹងថាបានទទួលកាលពីឆ្នាំមុន និងថវិកាជាក់ស្តែងដែលបានទទួល។ ព័ត៌មានក៏បង្ហាញអ្នកផងដែរ ថាតើមូលនិធិដែលទទួលបានច្រើនជាងឬតិចជាងការរំពឹងទុក។

## ចំណាយ

តើសាលារៀនអ្នកប្រើប្រាស់ថវិកាយ៉ាងដូចម្តេច?
ព័ត៌មានទាំងនោះនឹងប្រាប់ឲ្យអ្នកដឹងអំពីថវិកាសរុបដែល បានចំណាយសម្រាប់សាលារៀនអ្នកកាលពីឆ្នាំកន្លងមក។ វាក៏បង្ហាញប្រាប់អ្នកផងដែរអំពីថា តើសាលារៀន និងក្រសួងបានចំណាយថវិកាលើអ្វីខ្លះ។

**ឃុំ ក -- សាលាបឋមសិក្សា គ (២០១៤)** ២

**តើសាលាចំណាយថវិកាយ៉ាងដូចម្តេច?**

| | | |
|---|---|---|
| ក្នុងឆ្នាំ ២០១៤ សាលារៀនរបស់អ្នកបានចំណាយសរុបៈ | 45,850,000 | |
| គ្រប់គ្រងដោយសាលា | 9,500,000 | |
| ■ ប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្រៀន<br>កិច្ចប្រជុំ និងប្រាក់ឧបត្ថម្ភធ្វើការបន្ថែមម៉ោង | 1,000,000 | 2% |
| ■ រង្វាន់ និងអំណោយសម្រាប់សិស្ស<br>សម្ភារៈសម្រាប់មេរៀនសិល្បៈ សង្គម ហិរញ្ញវត្ថុ។ល។ | 2,000,000 | 4% |
| ■ ការថែទាំ និងទឹក ភ្លើងសម្រាប់សាលា<br>អគ្គិសនី ទឹក កន្លែងក្មេងលេង ដើមឈើ អនាម័យ | 1,000,000 | 2% |
| ■ តុបតែង និងសាងសង់<br>អនាម័យសាលា | 5,500,000 | 12% |
| ចំណាយផ្ទាល់ដោយក្រសួងអប់រំយុវជន និងកីឡា | 36,350,000 | |
| ■ ប្រាក់ខែ<br>នាយកសាលា គ្រូបង្រៀន ការឧបត្ថម្ភ និងបុគ្គលិកផ្សេងៗ | 34,000,000 | 74% |
| ■ សៀវភៅ និងសម្ភារៈមូលដ្ឋាន<br>សៀវភៅ សម្ភារៈសម្រាប់ប្រលង សម្ភារៈការិយាល័យ | 2,350,000 | 5% |

**តើការចំណាយរបស់សាលាកើនឡើងដែរឬទេ?**

? មិនដឹង
- ក្នុងឆ្នាំ 2013សាលាចំណាយ %.
- ក្នុងឆ្នាំ 2014សាលាចំណាយ 45,850,000
- កើនឡើង មិនដឹង

**តើការចំណាយរបស់សាលាដូចថវិកាគ្រោងដែរឬទេ?**

? មិនដឹង
- ក្នុងឆ្នាំ 2014 សាលាគ្រោងថវិកា
- ក្នុងឆ្នាំ 2014 សាលាបានចំណាយ 45,850,000
- ភាគរយចំណាយធៀបនិងថវិកាគ្រោង មិនដឹង

## ចំណាយដោយសាលារៀន

- ប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្រៀនៈ កិច្ចប្រជុំ និងប្រាក់ឧបត្ថម្ភធ្វើការបន្ថែមម៉ោង
- រង្វាន់ និងអំណោយសម្រាប់សិស្សៈ សម្ភារៈសម្រាប់មេរៀនសិល្បៈ សង្គម ហិរញ្ញវត្ថុ ។ល។
- ការថែទាំ និងទឹកភ្លើងសម្រាប់សាលាៈ អគ្គិសនី ទឹក កន្លែងក្មេងលេង ដើមឈើ អនាម័យ
- តុបតែង និងសាងសង់ៈ អនាម័យសាលា

## ចំណាយដោយក្រសួង

- ប្រាក់ខែៈ នាយកសាលា គ្រូបង្រៀន ការឧបត្ថម្ភ និងបុគ្គលិកផ្សេងៗ
- សៀវភៅ និងសម្ភារៈមូលដ្ឋានៈ សៀវភៅ សម្ភារៈសម្រាប់ប្រលង សម្ភារៈការិយាល័យ

## តើចំណាយសម្រាប់សាលារបស់អ្នកមានការកើនឡើងដែរឬទេ?

ព័ត៌មាននេះនឹងបង្ហាញពីថវិកាចំនួនប៉ុន្មានដោយសាលារៀនរបស់អ្នកកាលពី ២ ឆ្នាំកន្លងមក។ វាក៏បង្ហាញអ្នកផងដែរ ថាតើចំណាយមានការកើនឡើង ឬក៏ថយចុះគិតជាភាគរយ។

## តើការចំណាយថវិកាដោយសាលារៀនអ្នកតាមផែនការឬទេ?

ព័ត៌មាននេះនឹងបង្ហាញអ្នកអំពីថវិកាដែលរំពឹងទុកក្នុងការចំណាយសម្រាប់សាលារៀនអ្នក និងចំណាយជាក់ស្តែងកាលពីឆ្នាំមុន។ វាក៏បង្ហាញប្រាប់អ្នកផងដែរថាតើចំនួនដែលបានចំណាយច្រើនជាង ឬតិចជាងការរំពឹងទុកគិតជាភាគរយ។

អ្នកចាំបាច់ត្រូវដឹង ៣ចំណុចផ្សេងទៀតពាក់ព័ន្ធនឹងថវិការបស់សាលាបឋមសិក្សា

### ១. តើសាលាបឋមសិក្សាអ្នកទទួលបានថវិកាដូចការរំពឹងទុកឬទេ?

មានពេលខ្លះសាលារៀនមិនបានទទួលថវិកាដូចការរំពឹងទុកទេ។ ប្រការនេះនាំឲ្យមានការប៉ះពាល់ដល់ការសិក្សារបស់សិស្ស។

> ឧទាហរណ៍ៈ សាលារៀនរំពឹងថាទទួលបាន ៣៥.០០០.០០០រៀល។ ផ្ទុយទៅវិញសាលារៀនបានទទួលតែ ៣០.០០០.០០០ រៀល

### ២.តើចំណូល និងចំណាយរបស់សាលារៀនបានកើនឡើងរៀងរាល់ឆ្នាំដែរឬទេ?

ការទទួលបានព័ត៌មាននេះ នឹងជួយឲ្យអ្នកដឹងថាតើសាលារៀនមានលទ្ធភាពធ្វើឲ្យប្រសើរឡើងក្នុងការឆ្លើយតបតាមតម្រូវការរបស់សហគមន៍ដែរឬទេ។ ដូច្នេះ ជាការសំខាន់ដែលអ្នកត្រូវប្រៀបធៀបរវាងចំណូល និងចំណាយក្នុងឆ្នាំនេះ និងឆ្នាំមុន។

**ឧទាហរណ៍ៈ**

ឆ្នាំ២០១៤ ចំណូលមាន ៣៤.០០០.០០០រៀល។ ឆ្នាំ២០១៥ ចំណូលមាន ៣៦.០០០.០០០រៀល។
ឆ្នាំ២០១៤ ចំណាយមាន ៣៣.០០០.០០០រៀល។ ឆ្នាំ២០១៥ ចំណាយមាន ៣៦.០០០.០០០រៀល

### ៣. តើសាលារៀនបានចំណាយទៅតាមផែនការថវិកាដែរឬទេ?

ព័ត៌មាននេះ នឹងជួយឲ្យអ្នកដឹងថាតើសាលារៀនបានអនុវត្តតាមផែនការដែរឬទេ?

- ចំនួនថវិកាដែលសាលារៀនគ្រោងចំណាយ
- ចំនួនថវិកាដែលសាលារៀនបានចំណាយជាក់ស្តែង
- ភាគរយនៃថវិកាដែលបានចំណាយ

**ឧទាហរណ៍ៈ**

✓ បាទ — សាលាបានចំណាយ១០០% នៃថវិកាដែលបានគ្រោងទុក- ១០០%

នេះមានន័យថាសាលារៀនបានធ្វើការចំណាយថវិកាក្នុងចំនួនដូចគ្នាទៅនឹងចំនួនថវិកាដែលបានគ្រោងទុកក្នុងផែនការ។

☒ ទេ — សាលាមិនបានចំណាយ១០០% នៃថវិកាដែលបានគ្រោងទុក- ៨០%

នេះមានន័យថាសាលាមិនបានធ្វើការចំណាយថវិកាក្នុងចំនួនដូចគ្នាទៅនឹងចំនួនថវិកាដែលបានគ្រោងទុកក្នុងផែនការទេ

# លទ្ធផលនៃការបំពេញការងាររបស់សាលារៀន

រូបភាពផ្ទាំងធំនេះបង្ហាញអំពីការបំពេញការងាររបស់សាលាបឋមសិក្សា។ គ្រប់ព័ត៌មានទាំងនេះត្រូវបានប្រមូលពីសាលាបឋមសិក្សារបស់អ្នក។ អ្នកអាចធ្វើការពិនិត្យមើលពីការបំពេញការងាររបស់សាលារៀន ហើយអ្នកអាចផ្តល់នូវមតិយោបល់ដើម្បីធ្វើឲ្យការផ្តល់សេវារបស់សាលារៀនកាន់តែប្រសើរឡើង។




**តើអ្នកអាចស្វែងយល់ពីលទ្ធផលនៃការបំពេញការងាររបស់សាលារៀនដោយរបៀបណា?**

គ្រប់សាលាបឋមសិក្សានឹងបង្ហាញជាសាធារណៈនូវលទ្ធផល នៃការបំពេញការងាររបស់ខ្លួនពាក់ព័ន្ធនឹងស្តង់ដារ និងចំណុចដៅអប់រំជាតិ។ ក្នុងរូបភាពផ្ទាំងធំសម្រាប់ប្រជាពលរដ្ឋនឹងផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋលើសកម្មភាពស្តង់ដារសំខាន់ៗ ៦ចំណុច។ ការយល់ដឹងរបស់អ្នកអំពីព័ត៌មានទាំងនេះ មានសារៈប្រយោជន៍ណាស់ ហើយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងក្រុមប្រឹក្សាឃុំអាចជួយអ្នកបាន។

**តើស្តង់ដារលទ្ធផលនៃការបំពេញការងាររបស់សាលារៀនមានអ្វីខ្លះ?**

សាលាបឋមសិក្សាត្រូវផ្តល់នូវសេវាតាមស្តង់ដារជាតិអប់រំសម្រាប់គ្រប់សាលារៀន ដែលដាក់ចេញដោយក្រសួងអប់រំ យុវជន និងកីឡា។ ស្តង់ដារជាតិសំខាន់៤ចំណុចមានដូចខាងក្រោម៖

១. កុមារគ្រប់រូបចាប់ពីអាយុ៦ឆ្នាំឡើងទៅត្រូវទទួលបានការសិក្សាដោយឥតបង់ថ្លៃរហូតដល់ចប់ថ្នាក់ទី៩
២. គ្រូ១នាក់ទទួលបន្ទុក ១ថ្នាក់ ដែលមានសិស្សមិនលើសពី ៤២នាក់
៣. គ្រូត្រូវបង្រៀនរយៈពេល ២២៨ថ្ងៃ ក្នុងមួយឆ្នាំ
៤. សិស្សគ្រប់រូបត្រូវទទួលបានសៀវភៅពុម្ពចំនួន ៣ក្បាល ឬ៤ក្បាល ពីសាលារៀន ដោយឥតបង់ថ្លៃ

**ការប្រៀបធៀបលទ្ធផលនៃការបំពេញការងាររបស់សាលារៀនជាមួយស្តង់ដារអប់រំជាតិ**

**តើសាលារៀនរបស់អ្នកបានផ្តល់សេវាតាមតម្រូវការដែរឬទេ?**

តើសាលារៀនមានគ្រូគ្រប់គ្រាន់ដែរឬទេ?

សាលារៀនរបស់អ្នកត្រូវមានគ្រូពេញម៉ោង ១នាក់ សម្រាប់បង្រៀនសិស្ស ៤២នាក់

- កាលពីឆ្នាំកន្លងមក តើសាលារៀនអ្នកមានគ្រូ ១នាក់ សម្រាប់បង្រៀនសិស្ស៤២នាក់ឬទ?
- តើមានថ្នាក់រៀនប៉ុន្មាន នៅក្នុងសាលារៀនអ្នក?
- តើមានថ្នាក់រៀនប៉ុន្មាន ដែលមានគ្រូមួយនាក់បង្រៀនពេញម៉ោង?
- តើភាគរយនៃថ្នាក់រៀន ដែលមានគ្រូមួយនាក់បង្រៀនពេញម៉ោងមានប៉ុន្មាន?
- តើមានថ្នាក់រៀនប៉ុន្មាន ដែលមានសិស្ស ៤២នាក់ (ឬតិចជាង ៤២នាក់)?
- តើភាគរយនៃថ្នាក់រៀន ដែលមានសិស្ស៤២នាក់ (ឬតិចជាង ៤២នាក់) មានប៉ុន្មាន?

**ឧទាហរណ៍៖** នៅក្នុងសាលារៀន ក្នុងចំណោមថ្នាក់រៀនសរុប ២០ថ្នាក់ មាន ១០ថ្នាក់ដែលមានគ្រូមួយនាក់បង្រៀនពេញម៉ោង (៥០%) និង១៥ថ្នាក់មានសិស្ស ៤២នាក់ (ឬតិចជាង ៤២នាក់) (៧៥%)។

- កាលពីឆ្នាំកន្លងមក សាលាបឋមសិក្សារបស់អ្នកបានបំពេញតាមស្តង់ដារអប់រំជាតិ ដែលបានកំណត់ថា រាល់ថ្នាក់រៀនទាំងអស់ត្រូវមានគ្រូបង្រៀនពេញម៉ោងមួយនាក់ និងបង្រៀនសិស្ស៤២នាក់ ឲ្យបាន ១០០%។

**បាទ ចាស / ទេ**

# លទ្ធផលនៃការបំពេញការងាររបស់សាលារៀន

### តើសាលាបឋមសិក្សារបស់អ្នកបានផ្តល់ការបង្រៀនគ្រប់ថ្ងៃតាមការកំណត់ដែរឬទេ?

សាលាបឋមសិក្សារបស់អ្នកត្រូវផ្តល់ការបង្រៀន២២៨ថ្ងៃក្នុងមួយឆ្នាំ។ ករណីគ្រូខកខានមិនបានបង្រៀនតាមចំនួនថ្ងៃនេះទេ វានឹងប៉ះពាល់ដល់គុណភាពនៃការសិក្សារបស់សិស្ស៖

- កាលពីឆ្នាំកន្លងមក តើគ្រូនៅសាលារៀនរបស់អ្នកមានបានបង្រៀនគ្រប់២២៨ថ្ងៃក្នុងមួយឆ្នាំឬទេ? បាទ ចាស/ទេ
- តើនៅសាលារៀនរបស់អ្នក មានប៉ុន្មានថ្នាក់?
- តើមានថ្នាក់រៀនប៉ុន្មានដែលទទួលបានការបង្រៀនគ្រប់ ២២៨ថ្ងៃក្នុងមួយឆ្នាំ?

**ឧទាហរណ៍៖** កាលពីឆ្នាំកន្លងមក មានថ្នាក់ចំនួន ៧ក្នុងចំណោម ១៤ថ្នាក់ មានគ្រូមកបង្រៀនពេញ ២២៨ថ្ងៃ (៥០%)។ នេះមានន័យថា មានថ្នាក់រៀនពាក់កណ្តាល មានគ្រូមកបង្រៀនមិនគ្រប់ចំនួន ២២៨ថ្ងៃ។

### តើសាលាបឋមសិក្សារបស់អ្នកបានផ្តល់សៀវភៅពុម្ព តាមការកំណត់ដែរឬទេ?

សិស្សនៅក្នុងសាលាបឋមសិក្សារបស់អ្នក ចាប់ពីថ្នាក់ទី១ ដល់ទី៣ ត្រូវបានផ្តល់ ឬឲ្យខ្ចីសៀវភៅពុម្ពចំនួន ៣ក្បាល និងសិស្សថ្នាក់ទី៤ ដល់ថ្នាក់ទី៦ ត្រូវបានផ្តល់ ឬឲ្យខ្ចីសៀវភៅពុម្ពចំនួន ៤ក្បាល

- កាលពីឆ្នាំកន្លងមក តើមានសិស្សថ្នាក់ទី១ដល់ទី៣ និងសិស្សថ្នាក់ទី៤ ដល់ទី៦ ប៉ុន្មាននាក់ត្រូវបានផ្តល់ ឬឲ្យខ្ចីសៀវភៅពុម្ព? បាទ ចាស/ទេ
- តើសាលាបឋមសិក្សារបស់អ្នកបានផ្តល់ ឬឲ្យខ្ចីសៀវភៅពុម្ពដល់សិស្សតាមការកំណត់ដែរឬទេ? បាទ ចាស/ទេ

**ឧទាហរណ៍៖** កាលពីឆ្នាំកន្លងមក មានសិស្សថ្នាក់ទី១ដល់ទី៣ទាំងអស់ ត្រូវបានផ្តល់ ឬឲ្យខ្ចីសៀវភៅពុម្ពចំនួន ៣ក្បាល និងសិស្ស២០០នាក់ ក្នុងចំណោមសិស្ស៣០០នាក់ នៃថ្នាក់ទី៤ ដល់ថ្នាក់ទី៦ ត្រូវបានផ្តល់ ឬឲ្យខ្ចីសៀវភៅពុម្ព (៦៦%)។

### តើអ្វីខ្លះជាចំណុចដៅអប់រំជាតិ?

សាលាបឋមសិក្សារបស់អ្នកខិតខំសម្រេចឲ្យបានតាម "ចំណុចដៅ" អប់រំជាតិ ដើម្បីលើកកម្ពស់គុណភាព និងការពង្រីកវិសាលភាពនៃការអប់រំ។ ចំណុចដៅចំនួន៣ ដែលសាលារបស់អ្នកខិតខំសម្រេចឲ្យបានមានដូចខាងក្រោមនេះ៖

- យ៉ាងហោចណាស់ មានកុមារា និងកុមារីចំនួន៩០% មានអាយុ៦ឆ្នាំ បានចូលរៀននៅសាលាបឋមសិក្សា
- អត្រាសិស្សរៀនត្រួតថ្នាក់មិនត្រូវលើលពី ១០%នៃសិស្សសរុប
- កុមារចំនួន៨០% ត្រូវបានចូលរៀនចាប់ពីថ្នាក់ទី១ រហូតដល់ចប់ថ្នាក់ទី៦

### ដោយប្រៀបធៀបលទ្ធផលនៃការបំពេញការងាររបស់សាលារៀនអ្នកជាមួយនឹងចំណុចដៅអប់រំជាតិ តើលទ្ធផលនៃការបំពេញការងាររបស់សាលារៀនអ្នកល្អដែរឬទេ?

### តើសាលារៀនរបស់អ្នកសម្រេចបានតាមអត្រាចុះឈ្មោះចូលរៀនតាមការកំណត់ដែរឬទេ?

កុមារា កុមារី៩០% ដែលមានអាយុ៦ឆ្នាំ ត្រូវបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា

- កាលពីឆ្នាំកន្លងមក តើកុមារអាយុ៦ឆ្នាំ បានចុះឈ្មោះចូលរៀនប៉ុន្មានភាគរយ? (ស្វែងរកទិន្នន័យតើកុមារអាយុ៦ឆ្នាំមានប៉ុន្មាននាក់? និងបានចុះឈ្មោះចូលរៀនមានប៉ុន្មាននាក់? និងប៉ុន្មាននាក់មិនបានចុះឈ្មោះចូលរៀន)

**ឧទាហរណ៍៖** កាលពីឆ្នាំកន្លងមក កុមារចំនួន ១៨៥នាក់ ក្នុងចំណោម២០០នាក់ បានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា (៩៣%) ។

- តើកាលពីឆ្នាំកន្លងមក សាលារៀនរបស់អ្នកសម្រេចបានចំណុចដៅ៩០% ក្នុងការចុះឈ្មោះកុមារអាយុ៦ឆ្នាំឲ្យចូលរៀនដែរឬទេ? បាទ ចាស/ទេ

### តើសិស្សបានឡើងថ្នាក់ឬទេ? តើមានត្រួតថ្នាក់ឬទេ?

មានសិស្សតិចជាង១០%រៀនត្រួតថ្នាក់។ គ្រូត្រូវធានាថាសិស្សបានរៀនគ្រប់មេរៀន និងជំនាញដូចបានគ្រោងទុក ក្នុងកម្រិតសិក្សារបស់ពួកគេ។

- កាលពីឆ្នាំកន្លងមក តើមានសិស្សប៉ុន្មានភាគរយបានឡើងថ្នាក់? និងប៉ុន្មានភាគរយរៀនត្រួតថ្នាក់? (ស្វែងរកព័ត៌មាន តើកុមារប៉ុន្មាននាក់បានចុះឈ្មោះចូលរៀន? និងប៉ុន្មាននាក់រៀនត្រួតថ្នាក់?)

**ឧទាហរណ៍១៖** កាលពីឆ្នាំកន្លងមក កុមារ៦០០នាក់ បានចុះឈ្មោះចូលរៀន និងមិនមានកុមាររៀនត្រួតថ្នាក់ទេ (០%) ។

**ឧទាហរណ៍២៖** កាលពីឆ្នាំកន្លងមក កុមារ៥០០នាក់ បានចុះឈ្មោះចូលរៀន និងមានកុមារ១០០នាក់រៀនត្រួតថ្នាក់ (២០%)។

- កាលពីឆ្នាំកន្លងមក តើមានសិស្សលើលពី១០% បានរៀនត្រួតថ្នាក់ឬទេ? បាទ ចាស/ទេ

### តើសាលារៀនរបស់អ្នកសម្រេចបានតាមចំណុចដៅអប់រំជាតិដែលតម្រូវឲ្យរៀនចប់ថ្នាក់ទី៦ដែរឬទេ?

ចំណុចដៅអប់រំជាតិកំណត់ថា កុមារយ៉ាងតិច៨០% បានចុះឈ្មោះចូលរៀនចាប់ពីថ្នាក់ទី១ រហូតចប់ថ្នាក់ទី៦

- តើមានសិស្សដែលចាប់ផ្តើមរៀនពីថ្នាក់ទី១នៅសាលារៀនមានប៉ុន្មាននាក់រហូតដល់ចប់ថ្នាក់ទី៦? (ស្វែងរកព័ត៌មានតើមានកុមារប៉ុន្មាននាក់បានចូលរៀនថ្នាក់ទី១? តើមានប៉ុន្មាននាក់បានបោះបង់ការសិក្សា? តើមានប៉ុន្មាននាក់បានរៀនចប់ថ្នាក់ទី៦?)

**ឧទាហរណ៍៖** កាលពីឆ្នាំកន្លងមក ក្នុងចំណោមកុមារ១០០នាក់ ដែលបានចុះឈ្មោះចូលរៀននៅថ្នាក់ទី១ មាន១០នាក់បានបោះបង់ការសិក្សា និង៩០នាក់ទៀតបានរៀនចប់ថ្នាក់ទី៦ (៩០%)។ កាលពីឆ្នាំកន្លងមក ក្នុងចំណោមកុមារ ១២០នាក់ដែលបានចុះឈ្មោះចូលរៀននៅថ្នាក់ទី១ មាន៣០នាក់បានបោះបង់ការសិក្សា និង១២០នាក់បានរៀនចប់ថ្នាក់ទី៦ (៧៥%)។

- កាលពីឆ្នាំកន្លងមក តើសាលារៀនរបស់អ្នកសម្រេចបានតាមចំណុចដៅអប់រំជាតិដែលតម្រូវឲ្យរៀនចប់ថ្នាក់ទី៦ដែរឬទេ? បាទ ចាស/ទេ

នៅមានសូចនាករផ្សេងទៀត ដែលបង្ហាញពីលទ្ធផលនៃការបំពេញការងាររបស់សាលាបឋមសិក្សារបស់អ្នក ដែលអ្នកអាចយកមកប្រើប្រាស់បាន។

> ការបង្ហាញជាសាធារណៈអំពីព័ត៌មានរបស់សាលាបឋមសិក្សា
>
> - សាលារៀននឹងបង្ហាញជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធទៅនឹងថ្ងៃបើកបវេសនកាល ម៉ោងបង្រៀន ថ្ងៃឈប់សម្រាក សិទ្ធិ ស្តង់ដារអប់រំ ថវិកាប្រចាំឆ្នាំ ការបំពេញការងារ ផែនការអភិវឌ្ឍន៍វិស័យអប់រំ និងព័ត៌មានទំនាក់ទំនាក់ជាមួយសាលារៀន។

### យោបល់ និងសំណូមពរ

### តើអ្នកមានយោបល់ និងសំណូមពរឬទេ? មានជម្រើស៤សម្រាប់អ្នក៖

- អ្នកអាចនិយាយដោយផ្ទាល់ជាមួយគ្រូ ឬនាយកសាលា
- អ្នកអាចនិយាយដោយផ្ទាល់ជាមួយសមាជិកគណៈកម្មការទ្រទ្រង់សាលារៀន
- អ្នកអាចនិយាយដោយផ្ទាល់ជាមួយក្រុមប្រឹក្សាឃុំ
- អ្នកអាចប្រាប់ពីបញ្ហាដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ហើយមតិយោបល់ ឬសំណូមពររបស់អ្នក នឹងត្រូវបានដាក់បញ្ចូលទៅក្នុងប័ណ្ណដាក់ពិន្ទុសហគមន៍

# សិទ្ធិរបស់ប្រជាពលរដ្ឋ

រូបភាពផ្ទាំងធំនេះបរិយាយអំពីសិទ្ធិរបស់អ្នកនៅមណ្ឌលសុខភាព សិទ្ធិនេះរៀបចំឡើងដោយដកស្រង់ពីគោលការណ៍ណែនាំជាតិ សិទ្ធិរបស់អតិថិជន និងសិទ្ធិរបស់អ្នកផ្តល់សេវាសុខាភិបាល។




## សិទ្ធិរបស់អ្នកនៅមណ្ឌលសុខភាព

### អ្នកមានសិទ្ធិទទួលបានការយកចិត្តទុកដាក់ និងគោរពពីបុគ្គលិកមណ្ឌលសុខភាពដោយស្មើភាព

- បុគ្គលិកមណ្ឌលសុខភាពផ្តល់ជូនអ្នកនូវការគាំពារសុខភាព និងសេវាតាមតម្រូវការរបស់អ្នក
- អ្នកមានសិទ្ធិទទួលបានការពិគ្រោះ ពិនិត្យ និងព្យាបាលប្រកបដោយសេចក្តីថ្លៃថ្នូរ និងរួសរាយរាក់ទាក់ពីបុគ្គលិក មណ្ឌលសុខភាព
- នៅពេលទទួលសេវាថែទាំសុខភាព មិនមាននរណាម្នាក់ទទួលការរើសអើងដោយសារតែភេទ ជាតិសាសន៍ ពណ៌សម្បុរ ស្ថានភាពជីវភាព ស្ថានភាពនៅលីវ ឬរៀបការហើយ ការអសមត្ថភាពផ្លូវកាយ និងផ្លូវចិត្ត ជំងឺ អាយុ ភាសា សាសនា និងនិន្នាការនយោបាយ

### មណ្ឌលសុខភាពត្រូវបង្ហាញជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធនឹងសេវាដែលមាននៅមណ្ឌល

- អ្នកមានសិទ្ធិទទួលបានព័ត៌មានអំពីប្រភេទនៃសេវាសុខភាព ដែលមាននៅមណ្ឌលសុខភាព ម៉ោងបំពេញការងារ បែបបទដែលអតិថិជនត្រូវពិគ្រោះជំងឺ តារាងតម្លៃ និងករណីមិនបង់ថ្លៃ រួមទាំងរបៀបរបបបង់ថ្លៃសេវា
- អ្នកអាចសាកសួរព័ត៌មានបន្ថែម ដើម្បីឲ្យយល់កាន់តែច្បាស់

បុគ្គលិកនៅមណ្ឌលសុខភាពត្រូវជួយអ្នក ដើម្បីឲ្យអ្នកបានយល់ ពីបញ្ហាសុខភាព សាច់ញាតិ និងមិត្តរបស់អ្នក និងត្រូវរក្សាការសម្ងាត់

- អ្នកមានសិទ្ធិទទួលនូវការពន្យល់ណែនាំឲ្យយល់អំពីស្ថានភាពជំងឺ និងបញ្ហាសុខភាពរបស់អ្នក ដោយការយកចិត្តទុកដាក់ និងប្រើភាសាសាមញ្ញៗងាយយល់
- គ្រប់ព័ត៌មានអំពីបញ្ហាសុខភាពអ្នក ការព្យាបាល និងការសម្ងាត់នឹងត្រូវបានរក្សាទុកនៅកន្លែងមានសុវត្ថិភាព។

### បុគ្គលិកនៅមណ្ឌលសុខភាពត្រូវគិតថ្លៃសេវាព្យាបាលទៅតាមតារាងតម្លៃ

- អ្នកនឹងត្រូវបានប្រាប់អំពីតម្លៃសេវា និងរបៀបបង់ថ្លៃសេវា
- អ្នកនឹងមិនតម្រូវឲ្យបង់ថ្លៃសេវាលើសពីតារាងតម្លៃដែលបានកំណត់
- បុគ្គលិកមណ្ឌលសុខភាពមិនមានសិទ្ធិទទួលយកថ្លៃសេវាក្រៅផ្លូវការក្នុងការការផ្តល់សេវានានា

### អ្នកទទួលបានការរក្សាការសម្ងាត់ ជាពិសេសស្រ្តី

- អ្នកនឹងទទួលបានការក្សាការសម្ងាត់ ដែលធានាដោយបុគ្គលិកមណ្ឌលសុខភាព ក្នុងពេលអ្នកទទួលការព្យាបាល ជាពិសេសនៅពេលពិនិត្យសុខភាព និងព្យាបាលជំងឺ ជាពិសេសស្រ្តី
- ស្រ្តីគួរមានកន្លែងដាច់ដោយឡែកសម្រាប់ព្យាបាល
- អ្នកអាចប្រើប្រាស់បង្គន់អនាម័យដាច់ដោយឡែក ដែលដំណើរការបាន

### សុំការយល់ព្រម និងមតិយោបល់

- បុគ្គលិកមណ្ឌលសុខភាពត្រូវផ្តល់ព័ត៌មានអំពីជម្រើសនៃការថែរក្សា និងព្យាបាលសុខភាព និងលើកជាជម្រើសនានាដើម្បីឲ្យអ្នកធ្វើការសម្រេចចិត្តសមស្របសម្រាប់សុខភាពអ្នក
- មុនពេលព្យាបាល បុគ្គលិកមណ្ឌលសុខភាពនឹងសួរអ្នកថា តើអ្នកយល់ព្រមចំពោះវិធីសាស្រ្តព្យាបាលដែរឬទេ។ ក្រោយពីទទួលបានសេវា បុគ្គលិកមណ្ឌលសុខភាពនឹងសួរមតិយោបល់ត្រលប់របស់អ្នកអំពីសេវាដែលបានផ្តល់ជូន។

### ការទទួលខុសត្រូវរបស់អតិថិជន

ក្នុងនាមអតិថិជនដែលទៅរកសេវានៅមណ្ឌលសុខភាព អ្នកត្រូវធានាថាអ្នកទទួលបានសេវាថែទាំ និងព្យាបាលសុខភាពប្រកបដោយគុណភាពល្អ។

### មុននឹងទៅកាន់មណ្ឌលសុខភាព៖

- អ្នកគួរតែស្វែងយល់អំពីសិទ្ធិរបស់ខ្លួនឯង និងសាកសួរអំពីសិទ្ធិដែលអ្នកត្រូវទទួលបាន
- អ្នកគួរតែចូលរួមជាប្រចាំក្នុងសកម្មភាពលើកកម្ពស់សុខភាព និងថែរក្សាសុខភាព តាមការណែនាំរបស់បុគ្គលិកមណ្ឌលសុខភាព។

### ពេលអ្នកនៅមណ្ឌលសុខភាព៖

- អ្នកត្រូវផ្តល់ឯកសារ និងព័ត៌មានអំពីស្ថានភាពសុខភាពរបស់អ្នកឲ្យបានច្បាស់លាស់
- អ្នកត្រូវបង់ថ្លៃសេវាផ្លូវការ ហើយអ្នកមិនត្រូវបង់ថ្លៃសេវាក្រៅផ្លូវការទេ
- អ្នកត្រូវនិយាយរាក់ទាក់ និងសម្តែងការគួរសមជាមួយបុគ្គលិកមណ្ឌលសុខភាពដោយសុភាពរាបសារ និងការគោរព។

# ស្តង់ដារមណ្ឌលសុខភាព

រូបភាពផ្ទាំងធំនេះនឹងរៀបរាប់អំពីស្តង់ដារសេវាសុខភាពដែលមាននៅមណ្ឌលសុខភាព។ សិទ្ធិទាំងនេះគឺផ្អែកលើគោលការណ៍ណែនាំថ្នាក់ជាតិ និងកញ្ចប់អប្បបរមានៃសកម្មភាព (Minimal Package Activities)។




## អ្នកអាចរំពឹងថា មណ្ឌលសុខភាពរបស់អ្នកបំពេញតាមស្តង់ដារដូចតទៅ៖

### អ្នកអាចរំពឹងថា មណ្ឌលសុខភាពរបស់អ្នកត្រូវមានបុគ្គលិកពី៨ទៅ១១នាក់ ក្នុងអំឡុងម៉ោងធ្វើការ។

- មណ្ឌលសុខភាពរបស់អ្នកត្រូវមានបុគ្គលិកពី៨ទៅ១១នាក់ប្រចាំការ ដើម្បីផ្តល់សេវាសុខភាពសមស្រប និងចាំបាច់ដល់អ្នក
- មណ្ឌលសុខភាពនឹងបិទផ្សាយអំពីចំនួនបុគ្គលិកដែលត្រូវមានវត្តមានក្នុងមណ្ឌលសុខភាព

### អ្នកអាចរំពឹងថា មណ្ឌលសុខភាពរបស់អ្នក មានអ្នកប្រចាំការ ២៤ម៉ោងសម្រាប់សង្គ្រោះបន្ទាន់

- ក្នុងករណីសង្គ្រោះបន្ទាន់ អ្នកអាចទទួលបានការផ្តល់សេវា ២៤ម៉ោង ក្នុង១ថ្ងៃ
- ប្រសិនបើមិនមានវត្តមានបុគ្គលិកមណ្ឌលសុខភាពទេ អ្នកអាចទំនាក់ទំនងទៅកាន់ពួកគេបានតាមរយៈឈ្មោះទំនាក់ទំនង លេខទូរស័ព្ទ និងអាសយដ្ឋានដែលបានបិទបង្ហាញ។

# ស្តង់ដារមណ្ឌលសុខភាព

អ្នកអាចរំពឹងថា មណ្ឌលសុខភាពរបស់អ្នកទទួលបានការផ្គត់ផ្គង់ឱសថ ១២ដងក្នុង១ឆ្នាំ ដើម្បីធានាឲ្យមានឱសថគ្រប់គ្រាន់នៅក្នុងមណ្ឌលសុខភាព

ដើម្បីទទួលបានការថែទាំសុខភាព និងការព្យាលបាលគ្រប់គ្រាន់ មណ្ឌលសុខភាពរបស់អ្នកត្រូវមានឱសថសម្រាប់ព្យាបាលអ្នក។ ការិយាល័យប្រតិបត្តិស្រុក ត្រូវផ្គត់ផ្គង់ឱសថ១២ដងក្នុងមួយឆ្នាំ។

អ្នកអាចរំពឹងថា មណ្ឌលសុខភាពរបស់អ្នកមានកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការទ្រទ្រង់សុខភាព ១២ដង ក្នុង១ឆ្នាំ។

- ដើម្បីដោះស្រាយបញ្ហា និងលើកកម្ពស់មណ្ឌលសុខភាព មណ្ឌលសុខភាពរបស់អ្នកត្រូវមានកិច្ចប្រជុំគណៈកម្មការទ្រទ្រង់មណ្ឌលសុខភាពជារៀងរាល់ខែ។

អ្នកអាចរំពឹងថា មណ្ឌលសុខភាពរបស់អ្នក ត្រូវបិទផ្សាយព័ត៌មាន

- ព័ត៌មានអំពីសេវាទាំងអស់ សេវាដែលឥតបង់ថ្លៃ ម៉ោងធ្វើការ តម្លៃសេវា តារាងម៉ោងប្រចាំការ២៤ម៉ោង និងព័ត៌មានទំនាក់ទំនង ហើយព័ត៌មានអំពីថវិកាដែលត្រូវបិទផ្សាយជាសាធារណៈ។

**ការទទួលខុសត្រូវរបស់អ្នក**

អ្នកត្រូវទទួលខុសត្រូវក្នុងនាមជាអតិថិជន ដែលទៅរកសេវានៅមណ្ឌលសុខភាព ដើម្បីធានាថា អ្នកទទួលបានសេវាថែរក្សា និងព្យាបាលសុខភាព ប្រកបដោយគុណភាពល្អ

**មុននឹងទៅកាន់មណ្ឌលសុខភាព**

- អ្នកត្រូវគោរពម៉ោងការងារ និងរបៀបរបបទាក់ទងនៅពេលត្រូវការសង្គ្រោះបន្ទាន់
- អ្នកត្រូវធ្វើការទំនាក់ទំនងអំពីសេវាប្រចាំការ២៤ម៉ោង នៅពេលណាត្រូវការសេវាសង្គ្រោះបន្ទាន់តែប៉ុណ្ណោះ។ សម្រាប់សេវាមិនសង្គ្រោះបន្ទាន់ អ្នកត្រូវទៅពិនិត្យ ពិគ្រោះជំងឺនៅមណ្ឌលសុខភាពក្នុងម៉ោងការងារ

**នៅពេលអ្នកនៅមណ្ឌលសុខភាព**

- ក្នុងពេលពិគ្រោះជាមួយបុគ្គលិកមណ្ឌលសុខភាព អ្នកត្រូវសួរសំណួរទាំងឡាយដើម្បីធានាថាអ្នកបានយល់អំពីការថែទាំ ការព្យាបាល ការចេញវេជ្ជបញ្ជា និងការណែនាំអំពីការតាមដានជំងឺ
- ប្រសិនជាអាចធ្វើបាន អ្នកជំងឺត្រូវមកកាន់មណ្ឌលសុខភាពឲ្យបានទៀងទាត់ដើម្បីជារ ឬទទួលឱសថ ជៀសវាងមិនត្រូវឲ្យបងប្អូន ឬអ្នកជិតខាងមកទទួលឱសថជំនួស។
- អ្នកត្រូវចូលរួមថែរក្សាអនាម័យបង្គន់ឲ្យបានស្អាត

**បន្ទាប់ពីបានទទួលសេវា**

- អ្នកគួរផ្តល់មតិយោបល់ និងជូនដំណឹងដល់តំណាងរបស់អ្នកអំពីកង្វល់នានាដែលអ្នកមាន បន្ទាប់ពីបានទទួលសេវា
- អ្នកត្រូវជូនដំណឹងអំពីការសម្រេចចិត្ត និងសកម្មភាពនានារបស់មណ្ឌលសុខភាព គណៈកម្មការទ្រទ្រង់មណ្ឌលសុខភាព និងក្រុមប្រឹក្សាឃុំ

# ថវិការបស់មណ្ឌលសុខភាព

រូបភាពផ្ទាំងធំនេះបរិយាយអំពីព័ត៌មានពាក់ព័ន្ធនឹងថវិការបស់មណ្ឌលសុខភាព
របស់អ្នក និងលទ្ធផលនៃការបំពេញការងារ។
អ្នកអាចពិនិត្យមើលថាតើមណ្ឌលសុខភាពរបស់អ្នកចំណាយថវិកាលើអ្វីខ្លះ?




## វាពិតជាមានសារៈសំខាន់ក្នុងការដឹងអំពីថវិកាមណ្ឌលសុខភាពរបស់អ្នក

### ចំណូល

តើកាលពីឆ្នាំកន្លងមកមណ្ឌលសុខភាពរបស់អ្នកទទួលបានថវិកាប៉ុន្មាន? ខាងក្រោមនេះនឹងបង្ហាញអ្នកអំពីប្រភពថវិកាសរុបដែលមណ្ឌលសុខភាពបានទទួល។

**មណ្ឌលសុខភាព ឃ (២០១៤)** ១

**តើមណ្ឌលសុខភាពអ្នកទទួលថវិកាបានប៉ុន្មាន?**

| | | |
|---|---|---|
| ក្នុងឆ្នាំ ២០១៤ មណ្ឌលសុខភាពអ្នកទទួលថវិកា | 296,460,000 | |
| ថវិកាទាំងនោះបានមកពី៖ | | |
| ■ ថវិកាជាតិ<br>ថវិកាពីក្រសួង | 228,000,000 | 77% |
| ■ មូលនិធិសមធម៌សុខាភិបាល<br>ចំណូលបានពីថ្លៃសេវា ដែលផ្តល់ចំពោះ អ្នកទទួលបាន មូលនិធិសមធម៌សុខាភិបាល | 58,000,000 | 20% |
| ■ ជំនួយ និងការបរិច្ចាក<br>ប្រភពនៃអំណោយ ឬការបរិច្ចាកមិនត្រូវបានដឹង | 9,679,000 | 3% |
| ■ ថ្លៃប្រើប្រាស់<br>ដែលបានបង់ចំណូល ដោយអ្នកជំងឺ ដែលមកមណ្ឌលសុខភាព | 781,000 | 0% |

**តើចំណូលរបស់មណ្ឌលសុខភាពអ្នកមានការកើនឡើងឬទេ?**

? មិនដឹង

| | |
|---|---|
| • ក្នុងឆ្នាំ ២០១៣ មណ្ឌលសុខភាពបានទទួល | %. |
| • ក្នុងឆ្នាំ ២០១៤ មណ្ឌលសុខភាពបានទទួល | 296,460,000 |
| • កើនឡើង | មិនដឹង |

**តើមណ្ឌលសុខភាពអ្នកបានទទួលថវិកាតាមការគ្រោងដែរឬទេ?**

? មិនដឹង

| | |
|---|---|
| • ក្នុងឆ្នាំ ២០១៤ មណ្ឌលសុខភាពរំពឹងទទួលបាន | |
| • ក្នុងឆ្នាំ ២០១៤ មណ្ឌលសុខភាពទទួលជាក់ស្តែង | 296,460,000 |
| • %នៃថវិកាដែលទទួលបានជាក់ស្តែងគឺ | មិនដឹង |

### តើចំណូលមានប្រភពមកពីណា?

- ថវិកាជាតិ៖ ទទួលបានពីក្រសួងសុខាភិបាល
- មូលនិធិសមធម៌សុខាភិបាល៖ ចំណូលបានពីថ្លៃសេវាដែលផ្តល់ចំពោះអ្នកទទួលបានមូលនិធិសមធម៌សុខាភិបាល
- ជំនួយ និងការបរិច្ចាគ៖ ប្រភពនៃអំណោយ ឬការបរិច្ចាគ
- ថ្លៃប្រើប្រាស់៖ ដែលបានបង់ចំណូលដោយអ្នកជំងឺដែលមកមណ្ឌលសុខភាព

## ចំណាយ

តើកាលពីឆ្នាំកន្លងមក មណ្ឌលសុខភាពរបស់អ្នកបានចំណាយប៉ុន្មាន? តើកាលពីឆ្នាំកន្លងមក មណ្ឌលសុខភាពរបស់អ្នកប្រើប្រាស់ថវិកាលើអ្វីខ្លះ? ខាងក្រោមនេះនឹងបង្ហាញអ្នកអំពីការចំណាយថវិកាសរុបរបស់មណ្ឌលសុខភាពកាលពីឆ្នាំកន្លងមក


មណ្ឌលសុខភាព ឃ (២០១៤) ២

តើមណ្ឌលសុខភាពរបស់អ្នកបានចំណាយថវិកាយ៉ាងដូចម្ដេច?

| | | |
|---|---|---|
| ក្នុងឆ្នាំ ២០១៤ មណ្ឌលសុខភាពបានចំណាយសរុបចំនួនៈ | 263,010,258 | |
| ថវិកាត្រូវបានចំណាយទៅលើ | | |
| ■ ប្រាកខែ និងប្រាក់លើកទឹកចិត្តបុគ្គលិក<br>ប្រាក់ខែគោល យាមវេនយប់ និងប្រាក់លើកទឹកចិត្ត | 153,135,000 | 58% |
| ■ ឱសថ និងការផ្គត់ផ្គង់បន្ថែម<br>ចំណាយថ្លៃឱសថ និងផ្គត់ផ្គង់បន្ថែមដែលមិនបានផ្ដល់ដោយក្រសួង | 82,347,000 | 31% |
| ■ អ្នកជំងឺ និងការចុះតាមផ្ទះ<br>ថ្លៃធ្វើដំណើរសម្រាប់បុគ្គលិកមណ្ឌលសុខភាព អ្នកជំងឺ និងអាហារសម្រាប់អ្នកជំងឺ | 1,100,700 | 0% |
| ■ ចំណាយប្រតិបត្តិការ<br>ទឹក ភ្លើង សម្ភារៈការិយាល័យ ប្រេងសាំង និងការថែទាំ | 25,840,500 | 10% |
| ■ ប្រាក់ពន្ធកាត់ទុក ឬត្រូវបង់នៅ រតនាគារខេត្ត<br>១%នៃថ្លៃប្រើប្រាស់ ដែលបានកាត់ពន្ធទុក ឬត្រូវបង់នៅរតនាគារខេត្ត | 587,050 | 0% |

**តើការចំណាយរបស់មណ្ឌលសុខភាពមានការកើនឡើងឬទេ?**

? មិនដឹង

- ក្នុង ២០១៣ មណ្ឌលសុខភាពបានចំណាយ %.
- ក្នុង ២០១៤ មណ្ឌលសុខភាពបានចំណាយ 263,010,258

**តើមណ្ឌលសុខភាពអ្នកបានចំណាយដូចថវិកាគ្រោងដែរឬទេ?**

? មិនដឹង

- ក្នុង ២០១៤ ថវិកាគ្រោងចំណាយគឺ
- ក្នុង ២០១៤ ចំណាយជាក់ស្ដែងមាន 263,010,258

ខាងក្រោមនេះបង្ហាញពីទំហំចំណាយ និងមុខចំណាយ៖

- ប្រាក់ខែ និងប្រាក់លើកទឹកចិត្តរបស់បុគ្គលិក ជាចំណាយលើប្រាក់ខែគោល យាមវេនយប់ និងប្រាក់លើកទឹកចិត្ត
- ការទិញឱសថ និងការផ្គត់ផ្គង់បន្ថែម ចំណាយលើការទិញឱសថ និងសំភារៈផ្គត់ផ្គង់នានាដែលមិនបានផ្ដល់ដោយក្រសួង
- អាហារសម្រាប់អ្នកជំងឺ និងការចុះតាមផ្ទះ៖ថ្លៃធ្វើដំណើរសម្រាប់បុគ្គលិកមណ្ឌលសុខភាព អ្នកជំងឺ និងអាហារសម្រាប់អ្នកជំងឺ
- ចំណាយប្រតិបត្តិការ ចំណាយចាំបាច់នានា (អគ្គិសនី ទឹក សំរាម) សំភារៈការិយាល័យ ឥន្ធនៈ ការជួសជុល និងការថែទាំ
- ពន្ធរតនាគារខេត្ត ដែលស្មើនឹង១%នៃកម្រៃដែលទទួលបានពីសេវាត្រូវបង់ពន្ធទៅរតនាគារខេត្ត

## តើការចំណាយរបស់មណ្ឌលសុខភាពមានការកើនឡើងដែរឬទេ?

ព័ត៌មាននេះនឹងបង្ហាញអំពីថវិកាដែលបានចំណាយនៅមណ្ឌលសុខភាពសម្រាប់រយៈពេល២ឆ្នាំកន្លងមក។ ហើយវាក៏បង្ហាញនូវព័ត៌មានថាតើចំណាយសម្រាប់មណ្ឌលសុខភាពមានការកើនឡើង ឬក៏ថយចុះដោយគិតជាភាគរយ។

## តើមណ្ឌលសុខភាពចំណាយតាមផែនការថវិកាដែរឬទេ?

ព័ត៌មាននេះនឹងបង្ហាញអ្នកនូវអ្វីដែលមណ្ឌលសុខភាពបានរំពឹងថានឹងចំណាយកាលពីឆ្នាំកន្លងមក នឹងចំណាយជាក់ស្ដែង។ វាក៏បង្ហាញផងដែរថាតើចំនួនដែលបានចំណាយច្រើនជាង ឬក៏តិចជាងការរំពឹងទុក ដោយគិតជាភាគរយ។

# លទ្ធផលបំពេញការងាររបស់មណ្ឌលសុខភាព

រូបភាពផ្ទាំងធំនេះ បរិយាយអំពីព័ត៌មានពាក់ព័ន្ធនឹងលទ្ធផលបំពេញការងាររបស់មណ្ឌលសុខភាព។ អ្នកអាចធ្វើការត្រួតពិនិត្យថាតើមណ្ឌលសុខភាពរបស់អ្នក បំពេញការងារយ៉ាងដូចម្តេច និងអ្នកអាចផ្តល់ជាមតិយោបល់ដើម្បីធ្វើឲ្យការផ្តល់សេវារបស់មណ្ឌលសុខភាពកាន់តែប្រសើរឡើង។




## តើអ្នកអាចយល់ដឹងអំពីលទ្ធផលបំពេញការងាររបស់មណ្ឌលសុខភាពយ៉ាងដូចម្តេច?

នៅតាមមណ្ឌលសុខភាពនីមួយៗមានបិទផ្សាយជាសាធារណៈនូវព័ត៌មានអំពីលទ្ធផលនៃការផ្តល់សេវាសុខភាពដោយប្រៀបធៀបទៅនឹងស្តង់ដា និងចំណុចដៅជាតិសុខភាព។ ក្នុងរូបភាពផ្ទាំងធំសម្រាប់ប្រជាពលរដ្ឋនឹងផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋលើសកម្មភាពស្តង់ដារសំខាន់ៗ ៦ចំណុច

**តើអ្វីខ្លះជាស្តង់ដារបស់លទ្ធផលបំពេញការងាររបស់មណ្ឌលសុខភាព?**

មណ្ឌលសុខភាពរបស់អ្នកត្រូវអនុវត្តតាមស្តង់ដារជាតិសុខភាពដែលចេញដោយក្រសួងសុខាភិបាលសម្រាប់គ្រប់មណ្ឌលសុខភាពទាំងអស់។ ខាងក្រោមនេះនឹងបង្ហាញពចំណុចរបស់ស្តង់ដារជាតិសុខភាព៖

១. មានបុគ្គលិកពី៨នាក់ទៅ១១នាក់ប្រចាំការក្នុងម៉ោងការងារ ដើម្បីផ្តល់សេវាថែទាំសុខភាពដល់អ្នក តាមតម្រូវការរបស់អ្នក។

២. មានអ្នកប្រចាំការ២៤ម៉ោងសម្រាប់សេវាសង្គ្រោះបន្ទាន់រួមជាមួយព័ត៌មានទំនាក់ទំនង និងតារាងកាលវិភាគ

៣. ការផ្គត់ផ្គង់ឱសថ១២ដងក្នុង១ឆ្នាំដល់មណ្ឌលសុខភាពរបស់អ្នកដើម្បីធានាថា អ្នកមានឱសថគ្រប់គ្រាន់សម្រាប់បម្រើការព្យាបាល។

**ប្រៀបធៀបលទ្ធផលបំពេញការងាររបស់មណ្ឌលសុខភាពអ្នកជាមួយនឹងស្តង់ដាសុខភាពជាតិ**

**តើមណ្ឌលសុភាពរបស់អ្នកផ្តល់នូវសេវាដែលត្រូវការឬទេ?**

**តើមណ្ឌលសុភាពរបស់អ្នកមានបុគ្គលិកប្រចាំការគ្រប់គ្រាន់ឬទេ?**

- តើមណ្ឌលសុខភាពរបស់អ្នកត្រូវការបុគ្គលិកប៉ុន្មាននាក់? (៨ នាក់ ៩នាក់ ១០នាក់ ឬ១១នាក់)? (ចំនួនបុគ្គលិកនេះត្រូវបិទផ្សាយជាសាធារណៈ)
- កាលពីឆ្នាំកន្លងមក តើមណ្ឌលសុខភាពរបស់អ្នកមានបុគ្គលិកប៉ុន្មាននាក់បំពេញការងារក្នុងម៉ោងធ្វើការ?
- កាលពីឆ្នាំកន្លងមក តើមណ្ឌលសុខភាពរបស់អ្នកមានបុគ្គលិកធ្វើការតាមតម្រូវការឬទេ? បាទ ចាស/ទេ
- តើបុគ្គលិកទាំងនោះមានវត្តមានរៀងរាល់ម៉ោងធ្វើការឬទេ? បាទ ចាស/ទេ (ព័ត៌មាននេះរក្សាទុកនៅក្នុងបញ្ជីវត្តមាន)

**តើមណ្ឌលសុភាពរបស់អ្នកមានបុគ្គលិកប្រចាំការ២៤ម៉ោងឬទេ?**

- មណ្ឌលសុភាពរបស់អ្នកត្រូវមានបុគ្គលិកប្រចាំការ២៤ម៉ោង សម្រាប់សេវាសង្គ្រោះបន្ទាន់ រួមជាមួយការបិទផ្សាយព័ត៌មានទំនាក់ទំនង និងតារាងកាលវិភាគ
- កាលពីឆ្នាំកន្លងមក តើមណ្ឌលសុភាពរបស់អ្នកមានបុគ្គលិកប្រចាំការសម្រាប់ការហៅទូរស័ព្ទដើម្បីផ្តល់ការថែទាំសុខភាពឬទេ?
- កាលពីឆ្នាំកន្លងមក តើមណ្ឌលសុភាពរបស់អ្នកមានបុគ្គលិកប្រចាំការ២៤ម៉ោងឬទេ? បាទ ចាស/ទេ

# លទ្ធផលបំពេញការងាររបស់មណ្ឌលសុខភាព

## តើមណ្ឌលសុខភាពរបស់អ្នកមានឱសថគ្រប់គ្រាន់ឬទេ?

• មណ្ឌលសុខភាពរបស់អ្នកត្រូវទទួលបានការផ្គត់ផ្គង់ឱសថ១២ដងក្នុង១ឆ្នាំ ពោលគឺប្រមាណមួយដងក្នុង១ខែ ពីការិយាល័យប្រតិបត្តិស្រុក

• តើកាលពីឆ្នាំកន្លងមក មណ្ឌលសុខភាពរបស់អ្នកទទួលបានការផ្គត់ផ្គង់ឱសថប៉ុន្មានដង?

• តើកាលពីឆ្នាំកន្លងមក មណ្ឌលសុខភាពរបស់អ្នកទទួលបានការផ្គត់ផ្គង់ឱសថតាមផែនការឬទេ? បាទ ចាស/ទេ

## អ្វីទៅជាចំណុចដៅសុខភាពជាតិ?

មណ្ឌលសុខភាពរបស់អ្នកត្រូវសម្រេចឲ្យបានតាមចំណុចដៅសុខភាពជាតិ ដើម្បីធ្វើឲ្យប្រសើរឡើងនូវគុណភាពសេវា និងវិសាលភាពគ្របដណ្តប់នៃការថែទាំសុខភាព។

ខាងក្រោមនេះគឺជាចំណុចដៅសុខភាពជាតិចំនួន៣ ដែលមណ្ឌល សុខភាពរបស់អ្នកត្រូវសម្រេចឲ្យបាន៖

១. ស្ត្រីមានផ្ទៃពោះមកត្រូវមកពិនិត្យផ្ទៃពោះយ៉ាងហោចណាស់៤ដង មុនពេលសម្រាលកូន ដើម្បីធានាការលូតលាស់ និងតាមដានសុខភាពរបស់ទារក

២. ការសម្រាលកូនដោយសុវត្ថិភាពនៅក្នុងមណ្ឌលសុខភាពដោយឆ្មបជំនាញ ព្រោះមណ្ឌលសុខភាពត្រូវបានបំពាក់ និងមានបុគ្គលិកប្រកបដោយជំនាញក្នុងការរ៉ាប់រងស្ថានភាពស្មុគ្រស្មាញដែលមិនអាចប៉ាន់ស្មានមុន។

៣. ទារកត្រូវបានការពារពីជំងឺទាំងឡាយតាមរយៈការផ្តល់វ៉ាក់សាំងដល់ទារក អាយុក្រោម១ឆ្នាំដូចជាជំងឺខាន់ស្លាក់ ក្អក និង តេតាណូស (DPT3)។

## ប្រៀបធៀបលទ្ធផលបំពេញការងាររបស់មណ្ឌលសុខភាពអ្នកជាមួយនឹងចំណុចដៅសុខភាពជាតិ

## តើមណ្ឌលសុភាពរបស់អ្នកបំពេញការងារបានល្អឬទេ?

## តើមណ្ឌលសុខភាពរបស់អ្នកបានផ្តល់នូវសេវាថែទាំផ្ទៃពោះមុនពេលសម្រាលកូនតាមតម្រូវការដែរឬទេ?

• ដើម្បីធានាបានការលូតលាស់ និងការតាមដានសុខភាពទារក យ៉ាងហោចណាស់ ៨០% នៃស្ត្រីមានផ្ទៃពោះ គួរទទួលបានការពិនិត្យផ្ទៃពោះចំនួន៤ដងនៅមណ្ឌលសុខភាព។

• តើកាលពីឆ្នាំកន្លងមក មានស្ត្រីមានផ្ទៃពោះប៉ុន្មានភាគរយទទួលបានការពិនិត្យផ្ទៃពោះចំនួន៤ដង? (ស្វែងរកទិន្នន័យចំនួនស្ត្រីមានផ្ទៃពោះដែលបានទៅទទួលការពិនិត្យផ្ទៃពោះ និងក្នុងចំណោមនោះតើមានប៉ុន្មាននាក់ទទួលបានការថែទាំផ្ទៃពោះ ៤ដងពីគ្រូពេទ្យជំនាញ)

• តើកាលពីឆ្នាំកន្លងមក មណ្ឌលសុខភាពរបស់អ្នកសម្រេចបានតាមចំណុចដៅ៨០%ឬទេ? បាទ ចាស/ទេ

ការផ្តល់ព័ត៌មានជាសាធារណៈពីសេវាសុខភាព ដើម្បីឲ្យអ្នកបានដឹងអំពីសេវាទាំងឡាយ សេវាដែលមិនបង់ថ្លៃ ម៉ោងការងារ តារាងតម្លៃសេវា កាលវិភាគប្រចាំការ២៤ម៉ោង ព្រមទាំងព័ត៌មានទំនាក់ទំនាក់ និងថវិកា។

## តើមណ្ឌលសុខភាពអ្នកផ្តល់នូវសេវាសម្រាលកូនប្រកបដោយសុវត្ថិភាពដែរឬទេ?

• ស្ត្រីមានផ្ទៃពោះត្រូវសម្រាលកូននៅក្នុងមណ្ឌលសុខភាព ពីព្រោះមណ្ឌលសុខភាពមានសម្ភារៈបរិក្ខា និងបុគ្គលិកជំនាញក្នុងការរ៉ាប់រងស្ថានភាពស្មុគ្រស្មាញដែលមិនអាចប៉ាន់ស្មានមុន។ ការសម្រាលកូននៅមណ្ឌលសុខភាព មានសុវត្ថិភាពជាងការសម្រាលនៅផ្ទះ។

• តើកាលពីឆ្នាំកន្លងមក ស្ត្រីមានផ្ទៃពោះប៉ុន្មានភាគរយសម្រាលកូននៅក្នុងមណ្ឌលសុខភាព? (ស្វែងរកទិន្នន័យចំនួនស្ត្រីមានផ្ទៃពោះនៅក្នុងតំបន់ និងក្នុងចំណោមនោះតើមានប៉ុន្មាននាក់ទទួលបានការសម្រាលនៅក្នុងមណ្ឌលសុខភាព និងនៅកន្លែងផ្តល់សេវាសុខភាពដទៃទៀត)

• តើកាលពីឆ្នាំកន្លងមក មណ្ឌលសុខភាពរបស់អ្នកសម្រេចបានចំណុចដៅ៦៦%ដែលស្ត្រីមានផ្ទៃពោះសម្រាលកូននៅក្នុងមណ្ឌលសុខភាពឬទេ? បាទ ចាស/ទេ

## តើមណ្ឌលសុខភាពរបស់អ្នកបានផ្តល់វ៉ាក់សាំងចាំបាច់សម្រាប់ទារក ដែរឬទេ?

• ទារកអាយុក្រោម១ឆ្នាំត្រូវទទួលវ៉ាក់សាំង ខាន់ស្លាក់ ក្អក និងតេតាណូស (DPT3) ដើម្បីការពារជំងឺ។ តាមវិធីនេះគេរំពឹងថា យ៉ាងហោចណាស់៩៧%នៃទារកនឹងទទួលបានវ៉ាក់សាំងការពារនឹងជំងឺទាំងនេះ។

• តើកាលពីឆ្នាំកន្លងមក ទារកប៉ុន្មាននាក់បានទទួលបានវ៉ាក់សាំងពីមណ្ឌលសុខភាពរបស់អ្នក?
(ស្វែងរកទិន្នន័យចំនួនទារកសរុបដែលមានអាយុក្រោម១ឆ្នាំ ហើយតើប៉ុន្មាននាក់ទទួលបានវ៉ាក់សាំង?)

• តើកាលពីឆ្នាំកន្លងមក មណ្ឌលសុខភាពរបស់អ្នកផ្តល់វ៉ាក់សាំងដល់ទារក៩៧% នៃទារកទាំងអស់ដែរឬទេ? បាទ ចាស/ទេ

តើអ្នកមានយោបល់ និងសំណូមពរពាក់ព័ន្ធនឹងការបំពេញការងារ ឬថវិកាឬទេ? មានជម្រើស៤សម្រាប់អ្នកក្នុងការផ្តល់ជាមតិយោបល់៖

• អ្នកអាចពិភាក្សាជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងការដាក់បញ្ចូលទៅក្នុងប័ណ្ណដាក់ពិន្ទុសហគមន៍

• អ្នកអាចនិយាយជាមួយគណៈកម្មការទ្រទ្រង់មណ្ឌលសុខភាព ក្រុមគាំទ្រសុខភាពភូមិ ឬបុគ្គលិករបស់មណ្ឌលសុខភាព

• អ្នកអាចនិយាយជាមួយក្រុមប្រឹក្សាឃុំ

• អ្នកអាចប្តឹង ឬលើកជាសំណូមពរ សំណើដាក់ក្នុងប្រអប់សំបុត្រមតិយោបល់របស់មណ្ឌលសុខភាព

ព័ត៌មានបន្ថែម សូមទាក់ទងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍
ប្រធានមណ្ឌលសុខភាព នាយកសាលា ឬមេឃុំ។

ព័ត៌មានសម្រាប់ប្រជាពលរដ្ឋនេះត្រូវបានផលិតឡើងក្រោមកិច្ចគាំទ្រហិរញ្ញប្បទាន
សម្រាប់ភាពជាដៃគូក្នុងវិស័យអភិបាលកិច្ចនៃធនាគារពិភពលោក។